**បោះពុម្ពផ្សាយដោយ**
**គណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារ (គ.អ.ស.ក)**


**ទស្សនវិស័យ**

កុមារកម្ពុជាទទួលបាននូវសិទ្ធិពេញលេញរបស់ខ្លួនដូចមានចែងក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារ


**គណៈកម្មាធិការប្រតិបត្តិ**

លោកស្រី យឹម សុខារី ប្រធាន និងជានាយិកាប្រតិបត្តិ អង្គការកម្មវិធីជួយកុមារអនាថា និងអភិវឌ្ឍន៍

លោកមេធាវី អុប វិបុល អនុប្រធាន និងជាប្រធានកម្មវិធីយុត្តិធម៌កុមារ នៃអង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា

លោក ប៉ាវ វណ្ណៈ លេខាធិការ និងជាប្រធានអង្គការសហគមន៍សុវត្ថិភាពកុមារ

លោកបណ្ឌិត មែត់រ អេស ញឹម ហិរញ្ញឹក និងជានាយកប្រតិបត្តិអង្គការផេដវី

លោកស្រី អ៊ឹម ដារ៉ា សមាជិក និងជាប្រធានគម្រោង នៃអង្គការខ្មែរស្ម័គ្រចិត្ត ដើម្បីអភិវឌ្ឍន៍សហគមន៍

**អគ្គលេខាធិការ**

លោក មាស សំណាង

**យកព័ត៌មាន និពន្ធ និងក្រាហ្វិកកុំព្យូទ័រ**

លោក យុន ពិសី ប្រធានផ្នែកព័ត៌មាន

លោក ស៊ុន វិរៈ មន្ត្រីជាន់ខ្ពស់ទទួលបន្ទុកតាមដានសិទ្ធិកុមារ

កញ្ញា តាំង សុគន្ធា មន្ត្រីទទួលបន្ទុកធនធានឯកសារសិទ្ធិកុមារ

លោក អ៊ី តារា មន្ត្រីទទួលបន្ទុកព័ត៌មានវិទ្យា

យុវតី ឡាយ រតនា ប្រធានក្រុមគាំទ្រកុមារ

យុវជន បៀង វ៉ៃយ៉ា អនុប្រធានក្រុមគាំទ្រកុមារ

យុវតី អ៊ិត វិនដា សមាជិកក្រុមគាំទ្រកុមារ

យុវតី រុន ស្រីស្រស់ សមាជិកក្រុមគាំទ្រកុមារ

កុមារី ម៉ុន សម័យ សមាជិកក្រុមគាំទ្រកុមារ

**ឧបត្ថម្ភដោយ**

Plan
Be a part of it.

Save the Children



**អាសយដ្ឋានទំនាក់ទំនង:**
អគ្គលេខាធិការដ្ឋាន គ.អ.ស.ក
ផ្ទះលេខ 8A ផ្លូវលេខ ១៣៨ សង្កាត់វាលវង់ ខណ្ឌ៧មករា
រាជធានីភ្នំពេញ
ទូរស័ព្ទ: ០២៣ ៨៨២ ៩១២
អ៊ីមេល: info@ngocrc.org
គេហទំព័រ: www.ngocrc.org


## អង្គការសមាជិករបស់ គ.អ.ស.ក ឆ្នាំ២០១០

១.អង្គការជំនួយកុមារដើម្បីការរួបរួម និងការចូលរួម CAMP
២.សមាគមកុមារកម្ពុជាប្រឆាំងទុរភិក្ស និងហិង្សា CCASVA
៣.អង្គការសហគមន៍សុវត្ថិភាពកុមារ CCBO
៤.អង្គការអភិវឌ្ឍន៍កុមារកម្ពុជា CCD
៥.អង្គការគ្រីស្ទានកម្ពុជាដើម្បីអភិវឌ្ឍន៍ CCD
៦.អង្គការស្នងការជាតិកម្ពុជាដើម្បីអភិវឌ្ឍន៍ CCD
៧.មណ្ឌលកុមារដើម្បីសុភមង្គល CCH
៨.អង្គការកុមារកំព្រាកម្ពុជាសំរាប់ការរស់នៅ និងការអប់រំ CCOLT
៩.មជ្ឈមណ្ឌលកម្ពុជាដើម្បីការពារសិទ្ធិកុមារ CCPCR
១០.អង្គការការពារ និងសង្គ្រោះកុមារកម្ពុជា CCPSO
១១.អង្គការអ៊ីតាលីជួយសង្គ្រោះកុមារ CIAI
១២.សមាគមសិទ្ធិមនុស្សចាមខ្មែរអ៊ីស្លាមជនជាតិភាគតិច និងអភិវឌ្ឍន៍ CKIMHRDA
១៣.សមាគមកុមារ និងក្តីស្រឡាញ់ CLA
១៤.អង្គការកម្ពុជាដើម្បីកុមារ និងការអភិវឌ្ឍន៍ COCD
១៥.អង្គការអភិវឌ្ឍន៍កុមារ និងសហគមន៍ក្រីក្រ CPCDO
១៦.អង្គការមូលនិធិសិទ្ធិកុមារ CRF
១៧.អង្គការមូលនិធិគាំទ្រកុមារ CSF
១៨.អង្គការកុមារម្លប់ឆ័ត្រ CUCO
១៩.អង្គការខ្មែរស្ម័គ្រចិត្តដើម្បីអភិវឌ្ឍន៍សហគមន៍ CVCD
២០.អង្គការអភិវឌ្ឍន៍កូនខ្មែរវឌ្ឍនភាព DKKP
២១.អង្គការកុមារ និងអភិឌ្ឍន៍ E&D
២២.អង្គការអេវ្រីឆាលដ៍កម្ពុជា EvC
២៣.អង្គការហាការ HAGAR
២៤.អង្គកាបំរើសេវាសង្គមដើមឈើសប្បាយ Happy Tree
២៥.មជ្ឈមណ្ឌលថែទាំសុខភាពកុមារ HCC
២៦.អង្គការគ្រីស្ទានអន្តរជាតិ ICM
២៧.អង្គការអន្តរជាតិគាំទ្រកុមារ ICS
២៨.មូលនិធិកុមាររបស់ជែនីន និងប៊ីលី JBCF
២៩.អង្គការខេមរា KHEMARA
៣០.សមាគមខ្មែរកម្ពុជាក្រោមដើម្បីសិទ្ធិមនុស្សនិងអភិវឌ្ឍន៍ KKKHRDA
៣១.បណ្តាញកុមារឥតព្រំដែនកម្ពុជា KnK Network
៣២.អង្គការគ្រួសារថ្មី Krousar Thmey
៣៣.អង្គការខ្មែរទ្រទ្រង់សិទ្ធិកុមារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ KTO
៣៤.អង្គការយុវជនខ្មែរបោះជំរំដើម្បីវប្បធម៌ KYCC
៣៥.អង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា LAC
៣៦.អង្គការសម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស LICADHO
៣៧.អង្គការមិត្តសំឡាញ់ Mith Samlanh
៣៨.អង្គការប្រតិបត្តិការកុមារកម្ពុជា OEC
៣៩.អង្គការប្រឆាំងអំពើហិង្សាក្នុងគ្រួសារ PADV
៤០.អង្គការការពារយុត្តិធម៌កុមារ PJJ
៤១.អង្គការភ្លែន អន្តរជាតិ កម្ពុជា PLAN International
៤២.មូលនិធិសិទ្ធិកុមារតាមដងទន្លេ RKF
៤៣.អង្គការអូស្ត្រាលីសង្គ្រោះកុមារ SCA
៤៤.អង្គការកម្មវិធីជួយកុមារអនាថា និងអភិវឌ្ឍន៍ SCADP
៤៥.អង្គការន័រវេស៍្យសង្គ្រោះកុមារនៅកម្ពុជា SCNiC
៤៦.សមាគមអភិវឌ្ឍន៍គ្រួសារពលី និងកុមាកំព្រា SFODA
៤៧.អង្គការជំនួយក្មេងជំទង់ក្រីក្រ SIT
៤៨.អង្គការសុវណ្ណកុមារ Sovann Komar
៤៩.សហព័ន្ធយុវជនខ្មែរកម្ពុជាក្រោមដើម្បីលទ្ធិប្រជាធិបតេយ្យ UKYD
៥០.គណៈកម្មាធិការសំរបសំរួលអភិវឌ្ឍន៍ទីក្រុង USG
៥១.អង្គការគាំពារកុមារដែលងាយទទួលរងគ្រោះ VCAO
៥២.អង្គការអភិវឌ្ឍន៍វិជ្ជាជីវៈ និងអប់រំ VDTO
៥៣.សមាគមពន្លឺស្ត្រី WLA
៥៤.អង្គការវឌ្ឍនភាព WP
៥៥.អង្គការទស្សនៈពិភពលោក–កម្ពុជា WVC


**គណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារ**
**NGO COMMITTEE ON THE RIGHTS OF THE CHILD**

ព្រឹត្តិបត្រព័ត៌មាន ឆ្នាំទី ៨ លេខ ២៥ ខែមករា-ធ្នូ ឆ្នាំ២០១០


# ថ្ងៃ ១ មិថុនា ត្រូវបានកំណត់ជាទិវាកុមារកម្ពុជា និងជាថ្ងៃឈប់សម្រាកសាធារណៈឡើងវិញ




លោកជំទាវ **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ សំដែងសមានចិត្តចំពោះកុមារីសិល្បៈការិនី ដែលរាំរបាំស្វាគមន៍គណៈអធិបតីនាឱកាសមិទ្ទិញអបអរទិវាកុមារអន្តរជាតិ ១ មិថុនា ២០១០ នៅភ្នំពេញ

## មាតិកាព័ត៌មាន


» បញ្ហា ក្មេងទំនើង នៅតែជាបញ្ហាអាទិភាពដែលទាមទារឱ្យមានការចូលរួមលុបបំបាត់ទាំងអស់គ្នា .....................១
» ថ្ងៃ ១ មិថុនា ត្រូវបានកំណត់ជាទិវាកុមារកម្ពុជា និងជាថ្ងៃឈប់សម្រាកសាធារណៈឡើងវិញ.........................២
» ប្រុសឆ្លាតស៊ីធីអ៊ិន ដែលសាកសមជាយុវជនគំរូម្នាក់អតីតកុមារក្រីក្រមួយរូប ដែលបានចូលរួមយ៉ាងខ្លាំងក្លាជាមួយការងារអភិវឌ្ឍន៍សង្គម..................................៣
» ក្រឡេកមើលស្ថានភាពកុមារសុំទាននៅភ្នំពេញ............៥
» តំណាងក្រុមប្រឹក្សាឃុំ និងតំណាងកុមារក្នុងស្រុកសំរោងទទួលការបណ្តុះបណ្តាលពីសិទ្ធិកុមារ......................៧
» កុមារនិងយុវជនកម្ពុជាចូលរួមវេទិកាយុវជនមេគង្គនៅថៃ..៩
» តំណាងកុមារ និងយុវជនកម្ពុជាចូលរួមវេទិកាកុមារអាស៊ាន និងសិក្ខាសាលាថ្នាក់តំបន់ស្តីពីការលើកកំពស់ និងគាំទ្រការចូលរួមរបស់កុមារ និងយុវជនក្នុងអាស៊ាន .............១០
» ការធ្វើបច្ចុប្បន្នកម្មលើ របាយការណ៍ស្រមោលទាក់ទងទៅនឹងការអនុវត្តន៍សិទ្ធិកុមារនៅកម្ពុជា.......................១១
» ក្រុមកុមារ ពិគ្រោះយោបល់លើសេចក្តីព្រាងរបាយការណ៍ការអនុវត្តន៍ ពិធីសារបន្ថែម០២នៃអនុសញ្ញាសិទ្ធិកុមារ....១២
» អ្នកជំនាញជួបពិភាក្សាលើសេចក្តីព្រាងច្បាប់ យុត្តិធម៌អនីតិជន ...........................................១៣
» ក្រុមការងារចម្រុះយុត្តិធម៌អនីតិជន.......................១៤
» ច្បាប់ស្តីពីយុត្តិធម៌អនីតិជននឹងជួយអ្នកជាប់ឃុំប្រភេទនេះ
» កុមាររស់នៅក្នុងសិប្បកម្មឡឥដ្ឋ ៧៥% ធ្វើការចាប់ពីអាយុក្រោម ១២ ឆ្នាំ.......................................១៦
» ការរំលោភសេពសន្ថវៈកុមារកើនឡើងក្នុងឆ្នាំ ២០១០.....១៧
» កុមារមួយចំនួននៅតែប្រឈមនឹង ការមិនបានចូលសាលារៀន..............................................១៨

# បញ្ហា ក្មេងទំនើង នៅតែជាបញ្ហាអទិភាព ដែលទាមទារឱ្យមានការចូលរួមលុបបំបាត់ទាំងអស់គ្នា

បញ្ហាក្មេងទំនើង ហាក់មានសភាពស្ងៀមស្ងាត់បន្តិច បន្ទាប់ពីមានការចុះអន្តរាគមន៍ភ្លាមៗពីក្រសួងអប់រំ យុវជន និងកីឡា ទៅលើសាលារៀនមួយចំនួនធំ និងដោយការចូលរួមសហការពីកម្លាំងសមត្ថកិច្ច ដែលបានធ្វើការបង្ក្រាបករណីនេះជាបន្តបន្ទាប់។ តែទោះជាយ៉ាងនេះក្តី ក៏នៅក្នុងក្រសែភ្នែកមនុស្សជាច្រើន ពួកគេនៅតែជួប និងបានឃើញសកម្មភាពក្មេងទំនើងមួយចំនួន ដែលនៅតែបង្កនូវភាពអនាធិបតេយ្យ នៅតាមទីសាធារណៈ បង្កបញ្ហា និងការខឹងសម្បារដល់ប្រជាពលរដ្ឋ។



តំណាងកុមារមកពី១១រាជធានី-ខេត្តនៃបណ្តាញកុមារអ្នកតស៊ូមតិ ជួបប្រជុំប្រចាំត្រីមាស

បណ្តាញកុមារអ្នកតស៊ូមតិមកពី ១១ រាជធានី-ខេត្ត (Child Advocate Network) ហៅកាត់ថា ខេន (CAN) នៃគណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារ (NGOCRC) ដែលជាបណ្តាញក្រុមកុមារធ្វើការដើម្បីលើកកំពស់សិទ្ធិកុមារ បានកំណត់ឃើញនៅក្នុងកិច្ចប្រជុំប្រចាំត្រីមាសរបស់ខ្លួន កាលពីចុងខែមិថុនាថាបញ្ហាក្មេងទំនើង ជាបញ្ហាអទិភាពទី១ ក្នុងចំណោមបញ្ហាផ្សេងៗទៀតរបស់កុមារនៅក្នុងសហគមន៍ និងសាលារៀន។ បណ្តាញកុមារនេះបានរកឃើញតាមរយៈសកម្មភាពតាមដានរបស់សមាជិកខ្លួន ដែលមានចំនួនច្រើនជាង ២៨២ក្លឹប ថា បញ្ហាក្មេងទំនើង កើតមានឡើងស្ទើរទូទាំង ១១ រាជធានី-ខេត្ត នៃតំបន់គោលដៅការងាររបស់ពួកគេ។

កុមារា **គង់ សុវណ្ណដេត** ប្រធានបណ្តាញកុមារអ្នកតស៊ូមតិទាំង ១១រាជធានី-ខេត្ត និងជាសិស្សថ្នាក់ទី ១១ នៃវិទ្យាល័យស្វាយរៀង នៅទីរួមខេត្តស្វាយរៀង បានឱ្យដឹងថា ជារៀងរាល់៣ខែម្តង បណ្តាញកុមារអ្នកតស៊ូមតិតែងរៀបចំកិច្ចប្រជុំ ដើម្បីរាយការណ៍ពីសកម្មភាព ក៏ដូចជាស្ថានភាពកុមារក្នុងខេត្តនីមួយៗរបស់ខ្លួន ដើម្បីចែករំលែកនូវព័ត៌មាន និងពិភាក្សារកដំណោះស្រាយ និងលើកជាសំណូមពរទៅស្ថាប័នដែលពាក់ព័ន្ធ។ សំរាប់ត្រីមាសនេះ បញ្ហាក្មេងទំនើងគឺជាបញ្ហាអទិភាពទី១ដែលបណ្តាញកុមារបានរកឃើញ។ ភាគច្រើន នៃក្មេងទំនើងទាំងនោះ គឺជាក្មេងដែលបោះបង់ ការសិក្សា ឬមិនបានចូលរៀន ហើយគ្មានការងារធ្វើ និងជាក្មេងដែលគេចសាលាមិនព្រមចូលរៀន។

ជាមួយនឹងបញ្ហាខាងលើនេះ ក្រុម បណ្តាញកុមារអ្នកតស៊ូមតិបានមើលឃើញថា មូលហេតុដែលបណ្តាលឱ្យមានក្រុមក្មេងទំនើងកើតឡើងច្រើនគឺមកពីការសេពគប់មិត្តមិនល្អ នាំគ្នាដើរលេងមិនចូសាលា។ មួយវិញទៀតអាច មកពីគ្រួសារ និងអាណាព្យាបាល ដែលធ្វេសប្រហែស មិនបានតាមដានសកម្មភាព និងការសិក្សារបស់កូន រួមផ្សំនឹងភាពទំរើស យកចិត្តកូនពេក និងមិនមានឱកាសក្នុងការអប់រំទូន្មានកូន។

កត្តាមួយទៀតពាក់ព័ន្ធនឹងចំណេះដឹង ដែលមានកំរិតរបស់ឪពុកម្តាយ ដែលធ្វើឱ្យកុមារមិនស្តាប់បង្គាប់ ហើយគិតថាសំដីរបស់ពួកគាត់គ្មានប្រយោជន៍។ ចំពោះការគ្រប់គ្រងក្នុងសាលារៀនវិញ ក៏ជាកត្តាសំខាន់សម្រាប់ជំរុញឱ្យសិស្សចូលសាលារៀនដែរ។ បើសាលារៀនមានភាពធូររលុងពេក សិស្សមិនគោរពវិន័យ ហើយក៏មិនចង់ទៅរៀនដែរ។

សុវណ្ណដេត បានបន្ថែមទៀតថា *"នៅពេលដែលពួកគេប្រព្រឹត្តខ្លួនបែបនេះ វាធ្វើឱ្យបាត់បង់សណ្តាប់ធ្នាប់សង្គម មានភាពរញ៉េរញ៉ៃតាមទីសាធារណៈ ហើយការសេពគប់មិត្តភក្តិមិនល្អ អាចជ្រុលខ្លួនទៅជាអ្នកដើរលួចឆក់ប្រព្រឹត្តបទល្មើសផ្សេងៗ ដើម្បីយកប្រាក់ទៅទិញគ្រឿងញៀន ឬគ្រឿងស្រវឹង ដែលធ្វើឱ្យសង្គមស្អប់ខ្ពើម និងនាំឱ្យខូចអនាគតទៀតផង"* ។

ដើម្បីដោះស្រាយបញ្ហានេះ ក្រុមកុមារយល់ថា ត្រូវតែមានការចូលរួមទាំងអស់គ្នាពីអ្នកពាក់ព័ន្ធទាំងអស់ ដូចជា ឪពុកម្តាយ សាលារៀន សហគមន៍ អាជ្ញាធរ អង្គការ ក៏ដូចជាកុមារខ្លួនឯងផ្ទាល់។ យោងតាមកិច្ចពិភាក្សាក្នុងកិច្ចប្រជុំប្រចាំត្រីមាសរបស់បណ្តាញនេះ បានរកឃើញនូវដំណោះស្រាយ និងអនុសាសន៍មួយចំនួន ដើម្បីចូលរួមកាត់បន្ថយបញ្ហាក្មេងទំនើងនេះ។

ដំណោះស្រាយមួយ គឺក្រុមបណ្តាញកុមារអ្នកតស៊ូមតិដែលធ្វើការជាមួយកុមារ ត្រូវបន្តផ្សព្វផ្សាយ និងចុះអប់រំដល់កុមារក្នុងសហគមន៍មិនឱ្យយកគំរូតាមក្មេងទំនើង និងផ្តល់ព័ត៌មានដល់អាជ្ញាធរមានសមត្ថកិច្ច រាល់ពេលឃើញសកម្មភាពមិនប្រក្រតីណាមួយកើតឡើង។

ចំណែកអាជ្ញាធរមូលដ្ឋាន និងក្រសួងអប់រំគួរតែបន្តការផ្សព្វផ្សាយ និងបើកវគ្គបណ្តុះបណ្តាលដល់សិស្សតាមសាលារៀន និងឪពុកម្តាយសិស្ស ដើម្បីឱ្យពួកគាត់បានយល់ដឹងពីស្ថានភាពទូទៅរបស់កុមារក្នុងសង្គមបច្ចុប្បន្ន។ ចំពោះឪពុកម្តាយវិញ ត្រូវយកចិត្តទុកដាក់តាមដានពីសកម្មភាពរបស់កូនៗ ព្យាយាមទូន្មានអប់រំដោយសន្តិវិធី និង

ការប្រើពាក្យសម្តីឱ្យបានសមរម្យ ជៀសវាងការប្រើពាក្យត្រគោះបោះបោក។

គ្រួសារ និងសហគមន៍គួរតែផ្តល់ឱកាសឱ្យកុមារបានចូលរួមសកម្មភាពដែលទាក់ទងនឹងខ្លួនគេឱ្យបានច្រើនតាមតែអាចធ្វើទៅបាន ដើម្បីបង្កើននូវសមត្ថភាព និងចំណេះដឹង។ កុមារដែលបោះបង់ចោលការសិក្សា ត្រូវតែជំរុញឱ្យចូលរៀនវិញ និងជួយរកជំនាញផ្សេងៗ ឬការងារដែលសមស្របសំរាប់ពួកគេ ដើម្បីចៀសវាងកុំឱ្យចំណាយពេលវេលាឥតប្រយោជន៍ ទៅប្រព្រឹត្តអំពើមិនគប្បី។ ចំណែកកុមារខ្លួនឯងផ្ទាល់ ត្រូវព្យាយាមជៀសវាងការសេពគប់មិត្តភក្តិមិនល្អ និងខិតខំរៀនសូត្រ និងចូលរួមជួយការងារសង្គម ៕

***ដោយៈ យុវតី ឡាយ រតនា***

***ប្រធានក្រុមគាំទ្រកុមារ***

# ថ្ងៃ ១ មិថុនា ត្រូវបានកំណត់ជាទិវាកុមារកម្ពុជា និងជាថ្ងៃឈប់សម្រាកសាធារណៈឡើងវិញ

ទិវាកុមារអន្តរជាតិ ១ មិថុនា ដែលត្រូវបានផ្អាកលែងឱ្យជាថ្ងៃឈប់សម្រាកសាធារណៈរបស់រដ្ឋ តាំងពីឆ្នាំ ២០០៥មក ត្រូវបានរាជរដ្ឋាភិបាលកម្ពុជាក្រោមការសម្រេចដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា កំណត់ជាទិវាកុមារកម្ពុជា និងប្រកាសជាថ្ងៃឈប់សម្រាកការងាររបស់មន្ត្រីរាជការ និយោជិត កម្មករ ឡើងវិញចាប់ពីឆ្នាំ ២០១១ តទៅនេះបើយោងតាមសេចក្តីជូនដំណឹងរបស់ក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បីកុមារ ដែលមានឯកឧត្តម **អ៊ិត សំហេង** ជាប្រធាន ចុះថ្ងៃទី៩ សីហា ២០១០។

សេចក្តីសម្រេចនេះធ្វើឡើងបន្ទាប់ពីមានការលើកឡើងរបស់តំណាងកុមារកម្ពុជា ដែលបានថ្លែងក្នុងសុន្ទរកថាកុមារ នាឱកាសនៃការប្រារព្ធអបអរសាទរទិវាកុមារអន្តរជាតិ ខួបលើកទី ៦១ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់លោកជំទាវ **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជាតំណាងដ៏ខ្ពង់ខ្ពស់របស់សម្តេចតេជោ **ហ៊ុន សែន** កាលពីថ្ងៃ១ មិថុនា ២០១០។ បើយោងតាមរបាយការណ៍របស់គណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារ ដែលជាអង្គការដៃគូរបស់រដ្ឋាភិបាល ដែលបានចូលរួមយ៉ាងសកម្មក្នុងការរៀបចំទិវាកុមារអន្តរជាតិជាមួយក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារជារៀងរាល់ឆ្នាំ ឱ្យដឹងថា សំណើរបស់តំណាងកុមារឱ្យកំណត់យកថ្ងៃ ១ មិថុនា ជាថ្ងៃឈប់សម្រាកជាតិឡើងវិញនេះ ត្រូវបានធ្វើឡើងជារៀងរាល់ឆ្នាំចាប់តាំងពីឆ្នាំ ២០០៧ មក។ លុះរហូតដល់ឆ្នាំ ២០១០ នេះ ទើបលោកជំទាវ **ម៉ែន សំអន** បានទទួលយកសំណើរបស់តំណាងកុមារដាក់ឆ្លងសម្តេចនាយករដ្ឋមន្ត្រី និងគណៈរដ្ឋមន្ត្រី។

ជាមួយនឹងការសម្រេចចិត្តដ៏ឧត្តុង្គឧត្តម របស់រាជរដ្ឋាភិបាលនេះ កុមារា កុមារី និងប្រជាជនទូទៅ មានការភ្ញាក់ផ្អើល និងរំភើបរីករាយយ៉ាងក្រៃលែង ពីព្រោះពួកគេយល់ ថារាល់ទិវា ឬពិធីបុណ្យអ្វីមួយដែលរដ្ឋាភិបាលដាក់អោយឈប់សំរាកនោះ សុទ្ធសឹងតែជាថ្ងៃសំខាន់ ដែលទទួលបានការយកចិត្តទុកដាក់ខ្ពស់ពីរដ្ឋាភិបាល។



តំណាងកុមារថ្លែងចំណាប់អារម្មណ៍កុមារក្នុងឱកាសមិទ្ទិញអបអរទិវាកុមារអន្តរជាតិ ១ មិថុនា ២០១០

យុវជន **ឈឿន សុជឿន** អាយុ ១៩ឆ្នាំ តួនាទីមិត្តអប់រំមិត្តប្រចាំគូមិតារាម ឃុំចុងដាច់ ស្រុកតំបែរ ខេត្តកំពង់ចាម យល់ថា *"ចំពោះការដាក់បញ្ចូលថ្ងៃ ១មិថុនា ជាថ្ងៃឈប់សំរាកសំរាប់ប្រទេសកម្ពុជាយើង ជាការប្រសើរណាស់ ដោយសារកុមារបច្ចុប្បន្នមានសិទ្ធិ ៤ ដែលត្រូវតែបំពេញឱ្យយ៉ាងពេញលេញ។ ដូច្នេះ ពួកគេគួរមានថ្ងៃពិសេសសំរាប់ជីវិត ដើម្បីមានឱកាសបានឈប់សំរាក លេងល្បែងកំសាន្តរួមគ្នានៅតាមសាលា និងសហគមន៍ និងដើម្បីតបស្នងសងគុណដល់មាតាបិតា ដែលចិញ្ចឹមបីបាច់តាំងពីតូចមក"*។ សុជឿន ក៏បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះរដ្ឋាភិបាល ដែលបានដាក់បញ្ចូលថ្ងៃ ១ មិថុនាជាថ្ងៃឈប់សំរាក ដើម្បីឱ្យកុមារគ្រប់រូបបានរួចផុតពីពលកម្មធ្ងន់ធ្ងរ ការរំលោភបំពានគ្រប់រូបភាព និងមានតែភាពសប្បាយរីករាយក្នុងជីវិតរបស់ពួកគេ។

ចំណែក យុវនារី **ផាត ស្រីម៉ៅ** អាយុ ១៨ឆ្នាំ មានតួនាទីជាមិត្តអប់រំមិត្ត នៅគូមិជ័យសម្បត្តិ ឃុំតំបែរ ស្រុកតំបែរ ខេត្តកំពង់ចាម មានចំណាប់អារម្មណ៍មិនខុសពី សុជឿន ប៉ុន្មានទេ *"នាងខ្ញុំមានអារម្មណ៍សប្បាយយ៉ាងខ្លាំងចំពោះការដាក់បញ្ចូល ថ្ងៃ១មិថុនាជាថ្ងៃឈប់សំរាក ព្រោះថាកុមារគឺមានសិទ្ធិក្នុងការឈប់សំរាកលំហែកំសាន្ត។ ហើយការធ្វើបែបនេះ ធ្វើអោយកុមារបានដឹងថាពួកគេគឺមានតំលៃសំរាប់សង្គមជាតិ ហើយត្រូវសង្គមជាតិយកចិត្តទុកដាក់ និងទទួលស្គាល់តំលៃរបស់ពួកគេ។ ឆ្លៀតឱកាសនេះ ខ្ញុំសូមថ្លែង*

*អំណរគុណដល់រដ្ឋាភិបាលយ៉ាងខ្លាំងក្រៃលែង ដែលបានដាក់ថ្ងៃ ១មិថុនាជាថ្ងៃពិសេសសំរាប់កុមារ"*។

ដោយឡែក កុមារី ***ថូ សេងថៃ*** អាយុ១៧ឆ្នាំ ជាសិស្សថ្នាក់ទី១១ រស់នៅភូមិគោកស្រុក ឃុំគោកស្រុក ស្រុកតំបែរ ខេត្តកំពង់ចាម បានឱ្យអ្នកយកព័ត៌មានយើងដឹងដែរថា ប្អូនមានអារម្មណ៍សប្បាយណាស់សំរាប់ការដាក់បញ្ចូលថ្ងៃ១មិថុនា ជាថ្ងៃឈប់សំរាកសំរាប់កុមារ និងប្រជាជនប្រទេសកម្ពុជា ព្រោះថ្ងៃនេះជាថ្ងៃដែលកុមារបានបញ្ចេញមតិយោបល់ ហើយជាថ្ងៃដែលលើកកំពស់សិទ្ធិកុមារ។ ហើយឥឡូវនេះកុមារមានភាពក្លាហានក្នុងការអានចំណាប់អារម្មណ៍របស់គេ នៅថ្ងៃរំលឹកខួប១មិថុនា។ ជាពិសេសគេអាចអោយមនុស្សទូទៅ ដឹងថាកុមារក៏មានសិទ្ធិដែរ។ ប្អូនស្រីបានបន្តថា *"ខ្ញុំសប្បាយចិត្តបំផុតចំពោះរដ្ឋាភិបាលដែលបានយកចិត្តទុកដាក់ចំពោះកុមារ ។ នាងខ្ញុំសូមអរគុណក៏ដូចជាជូនពរដល់រដ្ឋាភិបាល អោយទទួលបានជោគជ័យគ្រប់ភារៈកិច្ច"*។

រីឯលោក **យឿង យាង** អាយុ៥០ឆ្នាំ រស់នៅភូមិត្រពាំងព្រីង ឃុំត្រពាំងព្រីង ស្រុកតំបែរ ខេត្តកំពង់ចាម មានតួនាទីជាសមាជិកក្រុមប្រឹក្សាឃុំ មានទស្សនៈថា *"ខ្ញុំយល់ឃើញថាវាការល្អ ក្នុងការដែលរដ្ឋាភិបាលបានដាក់បញ្ចូលថ្ងៃ១មិថុនាជាថ្ងៃឈប់សំរាក ។ ហើយខ្ញុំមានអារម្មណ៍សប្បាយរីករាយ និងចូលរួមអបអរសាទរចំពោះការដាក់បញ្ចូលនេះផងដែរ ។ ខ្ញុំបាទក៏សូមថ្លែងអំណរគុណដល់រដ្ឋាភិបាលដែលបានទទួលយកនូវសំណូមពររបស់កុមារ ហើយយកចិត្តទុកដាក់ និងអោយតំលៃចំពោះកុមារដែលជាទំពាំងស្នងឫស្សី"*។

ទន្ទឹមនឹងនេះដែរ លោក **សេន ស្លេះ** អាយុ៥៥ឆ្នាំ តួនាទីជាប្រធានក្រុមប្រឹក្សាកុមារថ្នាក់ឃុំ នៅភូមិអំពាក់២ ឃុំសេដា ស្រុកតំបែរ ខេត្តកំពង់ចាម មានប្រសាសន៍ថា *"ខ្ញុំយល់ឃើញថារដ្ឋាភិបាលមានការយកចិត្តទុកដាក់ខ្ពស់ចំពោះកុមារ ដែលបានដាក់បញ្ចូលថ្ងៃ១មិថុនាជាថ្ងៃឈប់សំរាកសំរាប់ប្រទេសយើង ។ ព្រោះថ្ងៃនេះគឺជាថ្ងៃសិទ្ធិរបស់កុមារ ដែលអាចបញ្ជាក់ថាកុមារក៏មានសិទ្ធិដូចមនុស្សពេញវ័យដែរ ។ ខ្ញុំសូមថ្លែងអំណរគុណចំពោះរដ្ឋាភិបាលដែលបានយកចិត្តទុកដាក់ចំពោះសិទ្ធិកុមារនៅក្នុងប្រទេសយើង"*។

ទាំងនេះសបញ្ជាក់អោយឃើញថា ទាំងកុមារ និងមនុស្សចាស់ ពេញចិត្ត និងគាំទ្រយ៉ាងពេញទំហឹង ចំពោះការដាក់បញ្ចូលថ្ងៃ ១ មិថុនា ទិវាកុមារអន្តរជាតិ ជាថ្ងៃឈប់សំរាក សំរាប់ប្រទេសកម្ពុជាឡើងវិញ។ ទិវានេះ នឹងផ្តល់ឱកាសឱ្យកុមារបានកំសាន្តសប្បាយជួបជុំឪពុកម្តាយ អាណាព្យាបាល លោកគ្រូ អ្នកគ្រូ បងប្អូន មិត្តភ័ក្តិទទួលអំណរសាទរ ហើយនៅតែចងចាំ និងចូលរួមលើកកម្ពស់សិទ្ធិកុមារនៅព្រះរាជាណាចក្រកម្ពុជាជានិរន្តរ៍ ៕

***ដោយៈ បៀង វីយ៉ា***

***អនុប្រធានក្រុមគាំទ្រកុមារ***

# ប្រុសឆ្លាតស៊ីធីអ៊ិន ដែលសាកសមជាយុវជនគំរូម្នាក់

## អតីតកុមារក្រីក្រមួយរូបដែលបានចូលរួមយ៉ាងខ្លាំងក្លាជាមួយការងារអភិវឌ្ឍន៍សង្គម


យុវជន អោម ចែតច័ន្ទណារ៉ា

នៅរៀងរាល់យប់ ក្នុងអំឡុងពេលសម្រាកពិសារអាហារពេលល្ងាច ចន្លោះម៉ោង ៧ ទៅម៉ោង ៨យប់ ប្រិយមិត្តដែលចូលចិត្តទស្សនាកម្មវិធីព័ត៌មានរបស់បណ្តាញទូរទស្សន៍កម្ពុជា ស៊ីធីអិន ប្រាកដជាបានឮការអានព័ត៌មាន របស់ពិធីករ-ពិធីការិនី ជាច្រើនរូបរបស់ស្ថានីយ៍ទូរទស្សន៍នេះ។ យុវជន **អោម ចែតច័ន្ទណារ៉ា** អាយុ២១ ឆ្នាំដែលជាអតីតជ័យលាភីប្រុសឆ្លាតឆ្នាំ ២០០៩ ជាពិធីករមួយរូប ក្នុងចំណោមពិធីករ-ពិធីការិនីអានព័ត៌មានជាច្រើនរូបរបស់ស្ថានីយ៍ទូរទស្សន៍ដ៏មានប្រជាប្រិយភាពនេះ។

ពិធីករវ័យក្មេងរូបនេះ បានទទួលចំណាត់ថ្នាក់លេខ១ ក្នុងកម្មវិធីប្រកួតប្រជែងសមត្ថភាពមួយឈ្មោះថា **"កម្មវិធីស្រីឆ្លាតប្រុសឆ្លាត២០០៩"** ដែលរៀបចំឡើងដោយស្ថានីយ៍ទូរទស្សន៍ស៊ីធីអិនជារៀងរាល់ឆ្នាំ ចាប់ពីឆ្នាំ ២០០៥ មក។ អតីតប្រុសឆ្លាត២០០៩ ដែលមានរូបសម្បត្តិស្រស់សង្ហារអំណោយផលពីធម្មជាតិ ទឹកដមសម្លេងមានភាពទាក់ទាញ និងបទពិសោធន៍ការងារសង្គមដ៏ច្រើន រូបនេះបាននិងកំពុងខិតខំប្រឹង ប្រែងកសាងកេរ្តិ៍ឈ្មោះ និងប្រជាប្រិយភាពក្នុងវិស័យសិល្បៈ ដែល កំពុងរីកចំរើនយ៉ាងខ្លាំងក្នុងសង្គមកម្ពុជាបច្ចុប្បន្ន។

ជាមួយនឹងទឹកមុខដ៏មានប្រជាប្រិយ រាងខ្ពស់ស្រឡះ មាឌធំ សម្បុរស និងសម្លេងពិរោះគួរឱ្យចង់និយាយលេងជាមួយ ណារ៉ា ជាអ្នកស្រុកខេត្តព្រះសីហនុ ដែលមានជីវភាពមិនសូវជាសំបូរបែបប៉ុន្មានទេ។ ឪពុកជាមន្ត្រីនគរបាល ម្តាយជាមេផ្ទះ និងមានបងប្អូន៤នាក់ ណារ៉ាជាកូនទី២ នៅក្នុងគ្រួសារ។ បើទោះជាមានជីវភាពមិនសូវធូរធារក៏ដោយ ក៏ណារ៉ាទទួលបាននូវភាពកក់ក្តៅ សុភមង្គល និងការគាំទ្រគ្រប់យ៉ាង

ពីគ្រួសារ ហើយបងប្អូនទាំងបួននាក់ សុទ្ធតែបានចូលរៀនគ្រប់ៗគ្នា។ ណារ៉ាបាននិយាយថា *"ខ្ញុំអាចឈានជើងមកដល់ពេលនេះ ព្រោះតែការតាំងចិត្ត និងការជួយជ្រោមជ្រែងពីគ្រួសាររបស់ខ្ញុំ"* ។

ណារ៉ា ដែលធ្លាប់ជាក្មេងដើរលក់កាសែតតាមហាងកាហ្វេ បានប្រលងជាប់សញ្ញាប័ត្រទុតិយភូមិ នៅខេត្តព្រះសីហនុក្នុងឆ្នាំ ២០០៨ ដោយការខិតខំប្រឹងប្រែងរៀនសូត្រ និងមានការជំរុញគាំទ្រ និងលើកទឹកចិត្តពីឪពុកម្តាយ។ សព្វថ្ងៃ ណារ៉ា ជានិស្សិតឆ្នាំទី២ នៃសាកលវិទ្យាល័យបៀលប្រាយ ផ្នែកអក្សរសាស្ត្រអង់គ្លេស នៅរាជធានីភ្នំពេញ និងជាទីប្រឹក្សារបស់ បណ្តាញកុមារអ្នកតស៊ូមតិ (ប.ក.ត) Child Advocate Network (CAN) នៃគណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារ (NGOCRC) ដែលមានការិយាល័យកណ្តាលនៅភ្នំពេញ និងតំបន់ប្រតិបត្តិការក្នុង ១១រាជធានី-ខេត្ត។

ពិធីកររូបសង្ហារម្នាក់នេះបានឱ្យដឹងទៀតថា ជីវិតរបស់លោក



ណារ៉ា (ជួរឈរទី៣ រាប់ពីឆ្វេង) និងសមាជិកបណ្តាញកុមារអ្នកតស៊ូមតិ ដែលជាតំណាងកុមារមកពី១១រាជធានី-ខេត្ត

បានចាប់ផ្តើមផ្លាស់ប្តូរក្នុងឆ្នាំ២០០៥ នៅពេលដែលលោក បានស្ម័គ្រចិត្តចូលជាសមាជិកក្លឹបក្រុមការពារកុមារ របស់អង្គការលីកាដូ ខេត្តព្រះ-សីហនុ។ សមត្ថភាពត្រឹមកុមារធម្មតាម្នាក់របស់គាត់ ត្រូវបានពង្រឹង និងអភិវឌ្ឍ តាមរយៈសកម្មភាព និងកម្មវិធីទាំងឡាយរបស់ក្លឹប។ នៅឆ្នាំ២០០៦ លោកក៏បាន ស្ម័គ្រចិត្តចូលជាសមាជិកបណ្តាញកុមារអ្នកតស៊ូមតិ (CAN) របស់អង្គការ NGOCRC និងជាសមាជិកនៃក្រុមចលនាកុមារ និងយុវជនដើម្បីសិទ្ធិកុមារ (CCYMCR) របស់អង្គការមូលនិធិសិទ្ធិកុមារ (CRF) បន្ថែមទៀត។ ការចូលរួមជាមួយក្លឹបកុមារ និងបណ្តាញកុមាររបស់អង្គការនានាខាងលើ បានធ្វើឱ្យភាពក្លាហាន សមត្ថភាពក្នុងការគិត ការនិយាយវែកញែក និងចំណេះដឹងសង្គមផ្សេងៗ ជាពិសេសចំណេះដឹងពាក់ព័ន្ធនឹងសិទ្ធិកុមារ របស់ណារ៉ាត្រូវបានដុសខាត់។ ទីបំផុតចំណេះដឹង និងបទពិសោធន៍ទាំងនេះ គួបផ្សំនឹងការតាំងចិត្ត និងការខិតខំព្យាយាមរបស់គាត់ ណារ៉ាត្រូវបានសមាជិកបណ្តាញកុមារអ្នកតស៊ូមតិ ចាត់ទុកជាសមាជិកឆ្នើមមួយរូប និងបោះឆ្នោតឱ្យធ្វើជាប្រធានរបស់បណ្តាញដែលមានសមាជិកក្នុង ១១រាជធានី-ខេត្ត នេះ ក្នុងឆ្នាំ២០០៧។

យុវជន **បៀង វ៉ៃយ៉ា** ជាអតីតប្រធាន CAN ជំនាន់ក្រោយណារ៉ា បាននិយាយថា *"សមាជិកក្នុងក្រុមទាំងអស់សុទ្ធតែចូលចិត្ត បងណារ៉ា ពីព្រោះគាត់តែងតែមានទំនាក់ទំនងល្អ និងជាមនុស្សឆ្លាត និងពូកែបង្កើតគំនិតថ្មីៗសំរាប់ក្រុមបណ្តាញកុមារយើង"*។ វ៉ៃយ៉ា បានបន្ថែមថា ណារ៉ាជាមនុស្សចូលចិត្តលេងសើចច្រើនដោយមិនប្រកាន់ខ្លួន និងរាប់អានមិត្តភក្តិ គ្រប់ប្រភេទទោះបីមុន និងក្រោយពេលគាត់ក្លាយជាតារាក៏ដោយ។ ជាងនេះទៅទៀត គាត់តែងតែចែករំលែកនូវចំណេះដឹង ពីការចូលរួមសកម្មភាពនានា ក៏ដូចជាបទពិសោធន៍ផ្សេងៗដែលគាត់មាន ទៅឱ្យសមាជិកក្រុមទៀតផង។

ក្នុងតួនាទីជាប្រធានបណ្តាញកុមារអ្នកតស៊ូមតិ និងជាសមាជិកក្លឹបកុមារ ណារ៉ា បានចូលរួមចំណែកក្នុងការងារ អភិវឌ្ឍន៍សង្គមជាច្រើនដូចជា: ចុះផ្សព្វផ្សាយពីបញ្ហាជួញដូរ កេងប្រវ័ញ្ចផ្លូវភេទ ទេសចរណ៍ផ្លូវភេទ និងពលកម្មកុមារ បញ្ហាសុខភាពបន្តពូជយុវវ័យ គ្រឿងញៀន ជំងឺអេដស៍ ជំងឺកាមរោគ បំនិនជីវិត ការពន្យាកំណើត ដល់ប្រជាពលរដ្ឋ អាណាព្យាបាល លោកគ្រូ អ្នកគ្រូ សិស្ស និស្សិត មន្ត្រីរាជការ អាជ្ញាធរ ម្ចាស់អាជីវកម្ម ម្ចាស់សិប្បកម្ម ម្ចាស់ផ្ទះសំណាក់ និងសណ្ឋាគារគ្រប់មជ្ឈដ្ឋាន ទាំងក្នុងទីប្រជុំជន ក៏ដូចជានៅតាមតំបន់មូលដ្ឋាននានា ក្នុងខេត្តព្រះសីហនុ ជាពិសេសដល់កុមារគ្រប់ប្រភេទ ដើម្បីឱ្យពួកគេយល់ដឹងពីសិទ្ធិរបស់ខ្លួន និងចេះការពារខ្លួនឱ្យចៀសផុតពីការរំលោភបំពានផ្សេងៗ ដូចជា កុមារធ្វើការនៅតាមឡូតិ៍នៃសាទ កុមាររើសសំរាម កុមារអនាថា កុមាររស់នៅក្នុងអង្គការ និងកុមារលក់ដូរនៅតាម ឆ្នេរសមុទ្រជាដើម។ ការផ្សព្វផ្សាយនេះធ្វើឡើងជាក្រុម តាមមធ្យោបាយជាច្រើនដូចជា: ដើរដង្ហែរជាក្បួន ការសំដែងរឿងខ្លី និពន្ធជាអត្ថបទរឿងអប់រំ តែងកំណាព្យ ការប្រគុំតន្ត្រីកម្មវិធីវេទិកាសាធារណៈ ច្រៀងចំរៀងអប់រំ កម្មវិធីសំនួរ-ចំលើយ កម្មវិធីជជែកតាមវិទ្យុ ការបោះជំរុំជួបជុំយុវវ័យ ការប្រជុំរាយការណ៍ប្រចាំខែដល់សមាជិកក្លឹប ។ល។ ណារ៉ាក៏ជាសមាជិកម្នាក់ របស់

បណ្ដាញការពារកុមារដែលមានតួនាទីឃ្លាំមើលសកម្មភាពរំលោភបំពានលើកុមារទាំងឡាយ ក្នុងសហគមន៍ផងដែរ។

*"ចំណេះដឹង បទពិសោធន៍ សមត្ថភាព ដែលខ្ញុំខំសន្សំ បានផ្ដល់ភាពជោគជ័យមកឱ្យខ្ញុំដោយនឹកស្មានមិនដល់ ព្រមទាំងជួយផ្ដល់ជាផ្លូវដើម្បីតំរង់ទិសដៅជីវិតរបស់ខ្ញុំទៀតផង"* ណារ៉ានិយាយដោយក្ដីរំភើប និងមោទនភាព។ លោកបានបន្តទៀតថា ការដែលលោកបានប្រលងជាប់ជាប្រុសឆ្លាតនេះ ក៏ដោយសារចំណេះដឹង និងបទពិសោធន៍ដ៏មានតម្លៃទាំងនោះ គួបផ្សំជាមួយនឹងទេពកោសល្យពីធម្មជាតិ ការខិតខំប្រឹងប្រែងហាត់លត់ដំខ្លួនដោយមិនខ្លាចការនឿយហត់ ការជួយតំរែតំរង់ពីអ្នកនៅជុំវិញ ជាពិសេសការគាំទ្រពីក្រុមគ្រួសាររបស់លោក។

លោក **មាស សំណាង** អគ្គលេខាធិការ នៃគណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារ (NGOCRC) បានឱ្យដឹងថា *"ណារ៉ាជាក្មេងម្នាក់ដែលមានភាពក្លាហាន មានការប្ដេជ្ញាចិត្តខ្ពស់ និងបានចំណាយពេលវេលាផ្ទាល់ខ្លួន ដើម្បីពង្រឹងនូវសមត្ថភាពឱ្យមានការទទួលស្គាល់ពីសង្គម"*។ លោកបានបន្ថែមទៀតថា អ្វីដែលធ្វើឱ្យណារ៉ាមានភាពជោគជ័យ ដូចថ្ងៃនេះគឺ ចរិតបែបវិជ្ជមានរបស់គាត់ដែលជួយឱ្យគាត់មានភាពលេចធ្លោនៅក្នុងចំណោមក្រុមកុមារ និងយុវជន ជាពិសេសគឺអាចឱ្យគាត់ចូលចុះទាំងក្នុងចំណោមកុមារ និងមនុស្សចាស់។ យើងក៏មិនអាចបដិសេធបានដែរ ថាជោគជ័យរបស់ណារ៉ា គឺបានមួយចំណែកមកពីបទពិសោធន៍ការងារ ដែលបានផ្ដល់ដោយបណ្ដាញកុមារអ្នកតស៊ូមតិ(CAN) និងស្ថាប័នអង្គការនានាដែលណារ៉ាបានចូលរួម។

លោកសំណាងបានបញ្ជាក់ទៀតថា ចំពោះរូបលោកផ្ទាល់ក៏ដូចជាក្រុមបណ្ដាញកុមារអ្នកតស៊ូមតិ មានមោទនភាព និងរីករាយយ៉ាងខ្លាំងនូវភ័ព្វសំណាង ព្រមទាំងជោគជ័យថ្មីរបស់ណារ៉ា ដែលបានក្លាយជាតារាមួយដួងក្នុងពិភពសិល្បៈ។ វាបានកែប្រែស្ថានភាពណារ៉ាពីក្មេងក្រីក្រធម្មតាម្នាក់ឱ្យទៅជាមនុស្ស ដែលមានគោលដៅជីវិតមួយច្បាស់លាស់ មានទំនួលខុសត្រូវលើខ្លួនឯង រៀនស្គាល់ពីការលំបាក ការប្រកួតប្រជែង ការរៀបចំអត្តចរិត ការនិយាយស្ដី និងសុជីវធម៌ក្នុងសង្គម ៕

***ដោយៈ គង់ អង្គារវលក្ខណ៍ និងឡាយ រតនា***





# កុមារសុំទាននៅភ្នំពេញ

## ក្រឡេកមើលស្ថានភាព

ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ រាជធានីភ្នំពេញមានការរីកចំរើនយ៉ាងខ្លាំង ជាពិសេសសំណង់អាគារ ហេដ្ឋារចនាសម្ព័ន សួនច្បារ កន្លែងកំសាន្ត និងជីវភាពរបស់ប្រជាជន មានការកែលំអ និងអភិវឌ្ឍន៍គួរឱ្យកត់សម្គាល់។ រៀងរាល់ល្ងាច នៅតាមទីសាធារណៈ សួនច្បារ និងកន្លែងកំសាន្តនានា ប្រជាជននៃទីក្រុងចំណាស់មួយនេះតែងប្រមូលផ្ដុំគ្នាសម្រាកលំហែរពីកិច្ចការប្រចាំថ្ងៃរបស់ខ្លួនជាមួយក្រុមគ្រួសារ មិត្តភ័ក្តិ ដែលបង្ហាញឱ្យឃើញពីជីវិត ស៊ីវិល័យទាន់សម័យថ្មីមួយ។

វេលារសៀលបន្តិច ក្នុងបរិវេណសួនច្បារសាធារណៈមួយនៅរមណីយដ្ឋានវត្តភ្នំ គេឃើញក្រុមកុមារដ៏អ៊ូអរ ប្រកបដោយសម្លៀកបំពាក់ទាន់សម័យ ទឹកមុខសប្បាយរីករាយ ចុះពីយានយន្តទំនើបៗ ប្រមូលផ្ដុំគ្នាយ៉ាងកក់ក្ដៅ ជាមួយឪពុកម្ដាយ និងក្រុមគ្រួសាររបស់ពួកគេ នាំគ្នាលេងកំសាន្តជាមួយនឹងសម្ភារៈកំសាន្តទំនើបៗ បរិភោគអាហារឆ្ងាញ់ៗ ហាក់គ្មានខ្វាយខ្វល់ពីអ្វីឡើយ។

ផ្ទុយទៅវិញ នៅមិនឆ្ងាយប៉ុន្មានពីទីនេះ នៅតាមបណ្ដោយសួនច្បារវត្តភ្នំ មុំសាកលវិទ្យាល័យជាតិគ្រប់គ្រង កុមារមួយក្រុមផ្សេងទៀត ស្ថិតក្នុងសំលៀកបំពាក់កខ្វក់រយីរយាកខ្វះមុខខ្វះក្រោយ រាងកាយស្គមស្គាំង ពោរពេញដោយស្នាមដំបៅ និងកាន់ក្អែល ទំនងខ្វះការសំអាតថែទាំ ទឹកមុខបង្កប់ដោយកង្វល់ និងការភ័យខ្លាច ខ្លះមានស្ពាយទារកតូចជាប់នឹងខ្លួនជាមួយក្រមាដ៏ចាស់ នាំគ្នាដើរតត្រុកស្វែងរកអំណោយជាប្រាក់កាស និងចំណីអាហារពីមនុស្សទាំងឡាយដែលមកអង្គុយលេងកំសាន្តម្ដុំនោះ។ កុមារខ្លះទៀតមានស្ពាយការុងចាស់ៗ ដើរកកាយតាមធុងសម្រាម ដើម្បីស្វែងរកសំណល់អាហារ កំប៉ុងភេសជ្ជៈដបទឹកសុទ្ធ ឬរបស់របរដែលអាចលក់យកលុយបាន។

ប្អូនស្រី ម៉ាប់ អាយុ១២ឆ្នាំ ដែលកំពុងចែកនំដែលសុំពីគេបានអោយទៅប្អូនប្រុសរបស់នាងបាននិយាយថា *"ការសុំទានមានការលំបាកណាស់ ត្រូវដើរទាំងថ្ងៃទាំងយប់ អ្នកខ្លះអាណិតក៏គេអោយទៅ អ្នកខ្លះគេជេស្ដី គេរើសអើង ។ ពេលបានបាយហូប មិនហ៊ានហូបអោយ*

*ឆ្អែតទេ ព្រោះទុកចំណែកខ្លះសម្រាប់ប្អូនប្រុស។ ថ្ងៃណាសុំបានលុយតិច ម្តាយចុងនឹងរករឿងហើយអោយហូបមិនឆ្អែតទៀត*"។ ម៉ាប់បានបន្តទាំងអោនមុខចុះថា រាល់ថ្ងៃប្អូនខ្មាស់គេណាស់ តែប្អូនគ្មានជម្រើសផ្សេងពីនេះទេ។ ប្អូនពិតជាចង់រៀនណាស់ ព្រោះមិនចង់ធ្វើបែបនេះរហូតទេ ហើយកាលពីមុនធ្លាប់មានអង្គការមួយចំនួនឱ្យប្អូនទៅនៅរៀនក្នុងមណ្ឌលដែរ តែពេលនេះប្អូនត្រូវត្រលប់មករស់នៅជាមួយឪពុក និងប្អូនប្រុសវិញ ដើម្បីរកលុយយកទៅឱ្យម្តាយចុង និងចិញ្ចឹមប្អូនប្រុស។

ប្អូនស្រីបានបន្តទាំងទឹកមុខក្រៀមក្រំទៀតថា ប្អូនមានបងប្អូនបីនាក់។ មុនម្តាយប្អូនស្លាប់៩ខែ បងស្រីរបស់ប្អូនបានរៀបការជាមួយជនជាតិចិនម្នាក់ ហើយក៏បាត់ដំណឹងចាប់ពីពេលនោះមក ដោយទុកអោយប្អូន និងប្អូនប្រុសរស់នៅជាមួយឪពុក។ លុះប្រហែលជាមួយឆ្នាំក្រោយមកឪពុកប្អូន ក៏បានយកប្រពន្ធចុងមួយទៀត ហើយប្រហែលជា១ខែក្រោយមក ម្តាយចុងបានអោយប្អូនឈប់រៀនហើយនាំប្អូនប្រុសកំសត់មកសុំទាននៅភ្នំពេញ។ ចំណែកឯឪពុកប្អូនវិញ មិនហ៊ាននិយាយអ្វីឡើយ។ ចាប់ពីពេលនោះមករាល់ពេលព្រឹក ម៉ាប់តែងតែនាំប្អូនជិះម៉ូតូឌុបពីគីឡូម៉ែតលេខ៦នៃខណ្ឌឬស្សីកែវ មកសុំលុយ និងរើសសំបកកំប៉ុងអេតចាយនៅកណ្តាលក្រុងភ្នំពេញ។

ជាមួយនឹងសំលៀកបំពាក់មិនសូវសមសួន ប្អូនស្រីអាយុ១៣ឆ្នាំម្នាក់ បានបីប្អូនប្រុសដ៏តូចដែលទើបតែមាន អាយុ៤ខែ មកសុំលុយ និងអាហារនៅតាមសួនច្បារខាងមុខសាកលវិទ្យាល័យជាតិគ្រប់គ្រង។ ប្អូនបាននិយាយថា សព្វថ្ងៃដោយសាតែគ្រួសារមានជីវភាពក្រីក្រលំបាកពេក ហើយមានបងប្អូនរហូតដល់ទៅ៧នាក់ ចំនែកឯឪពុកម្តាយវិញក៏មិនមានការងារធ្វើដែរ ណាមួយមិនមានទីលំនៅផងនោះនាង និងគ្រួសារក៏សំរេចចិត្តមកសុំទានដើម្បីដោះស្រាយ ជីវភាពគ្រួសារ។

តាមរយៈការសុំលុយ ក្នុងមួយថ្ងៃ ប្អូនបានបញ្ជាក់ថា អាចសុំបានពី ៧០០០រៀល ទៅ ៨០០០រៀល ហើយលុយទាំងអស់នោះគឺយកទៅឱ្យម្តាយ ដើម្បីទិញបាយ និងទឹកដោះគោឱ្យប្អូន។ ចំពោះទីកន្លែងដែលប្អូនសុំជាប្រចាំ គឺនៅមុខសាកលវិទ្យាល័យជាតិគ្រប់គ្រង។ ប៉ុន្តែជាធម្មតាគេតែងតែឃើញមានក្មេងៗ សុំលុយនៅតាមកន្លែងជាច្រើនទៀត ដូចជានៅម្តុំសួនច្បារមុខព្រះបរមរាជវាំង សួនច្បារសម្តេចហ៊ុនសែន មុខសណ្ឋាគារណាហ្គាវើល និងនៅវត្តភ្នំជាដើម។

កញ្ញា **សយ ភារម្យ** អាយុ២២ឆ្នាំ ជានិស្សិតឆ្នាំទី៣នៃសាកលវិទ្យាល័យវ៉ាន់ដាគណនេយ្យ ដែលកំពុងអង្គុយមើលមេរៀនជាមួយមិត្តភ័ក្តិបណ្តើ ញុំាបាយក្រៀមបណ្តើនៅសួនវត្តភ្នំនេះ បាននិយាយថា "*រាល់ពេល ខ្ញុំមកអង្គុយលេងតាមសួនម្តងៗ ខ្ញុំតែងតែឱ្យលុយទៅក្រុមក្មេងទាំងនោះចាប់ពី ២០០ ទៅ ៣០០០រៀល ពីព្រោះតែមានចិត្តអាណិតអាសូរ ដោយដឹងថាក្មេងៗទាំងនោះមិនបានចូលរៀន និងមានជីវភាពខ្វះខាត*"។

ចំណែកឯ កញ្ញា **ចេង អាយ** អាយុ ២៤ ឆ្នាំ ជានិស្សិតឆ្នាំទី២ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ដែលកំពុងហូបពោតជាមួយមិត្តភក្តិ នៅលើវាលស្មៅខៀវខ្ចីខាងមុខសណ្ឋាគារណាហ្គាវើលវិញ បានឱ្យដឹងថា "*ក្មេងៗទាំងនោះពិតជាគួរឱ្យអាណិតមែន ប៉ុន្តែបើយើងនៅតែបន្តឱ្យលុយទៀត ប្រៀបដូចជាលើកទឹកចិត្តអោយពួកគេបន្តការសុំទានរហូត*" ។ កញ្ញាបន្តទៀតថា នាងនិយាយនេះ គឺក្នុងន័យអាណិតស្រលាញ់ ចង់ឱ្យពួកគេចេះតស៊ូព្យាយាមក្នុងជីវិត មិនត្រូវផ្តេកផ្តួលតែលើការសុំទានមួយមុខនោះទេ។

ចំណែកលោកពូ **រស់ សម្បត្តិ** អាយុ ៤២ឆ្នាំ ដែលកំពុងអង្គុយលើ ធុក ធុក ស្តាប់បទចម្រៀង និងរង់ចាំភ្ញៀវរបស់គាត់នៅមុខសណ្ឋាគាររ៉ាហ្វលឡឺរ៉ូយាល់ក្បែរសួនវត្តភ្នំ បានមានប្រសាសន៏ឱ្យដឹងថាតាមការសង្កេតរបស់គាត់ឃើញថា ក្រុមកុមារទាំងនេះ មិនបានគិតពីអនាគតរបស់ពួកគេទេ ពួកគេគ្រាន់តែដើរសុំទានឱ្យបានលួមនឹងទិញបាយហូបហើយពួកគេនឹងឈប់គិតពីអ្វីទាំងអស់។ លោកពូបន្ថែមទៀតថា ភាគច្រើនពួកគេមានគ្រួសារមកជាមួយដែរ តែដូចជាមិនមានការយកចិត្តទុកដាក់លើពួកគេទេ ហើយបើនៅតែយ៉ាងនេះ មិនដឹងថាអនាគតពួកគេនឹងទៅជាយ៉ាងណានោះទេ។



លោក **ទេព ភិរុណ** បុគ្គលិក ផ្នែកសង្គមនៃ សមាគមន៍កុមារកម្ពុជា ប្រឆាំង ទុរភិក្ស និងហិង្សា ( CCASVA )

ឆ្លើយតបទៅនឹងបញ្ហាខាងលើ លោក **ទេព ភិរុណ** បុគ្គលិកផ្នែកសង្គមនៃ សមាគមន៍កុមារកម្ពុជា ប្រឆាំងទុរភិក្ស និងហិង្សាហៅកាត់ "ស៊ីកាស្វា" Cambodian Children Against Starvation and Violence ( CCASVA ) មានប្រសាសន៏ថា សព្វថ្ងៃអង្គការរបស់លោកបាន និងកំពុងអនុវត្តគំរោងមួយ ដែលធ្វើការជាមួយកុមារនៅតាមចិញ្ចើមថ្នល់ ផ្តោតលើកុមារដើរសុំលុយ រើសអេតចាយ និងធ្វើការតាមយានដ្ឋានលាងរថយន្តជាដើម ។

លោក ភិរុណ យល់ឃើញថា "ទោះបីជាស្ថានភាពកុមារមួយចំនួនបានល្អប្រសើរក៏ដោយ ក៏ចំនួនកុមារសុំទានមកពីខេត្តនានានៅភ្នំពេញ នៅតែមានការកើនឡើងដដែល ដោយសារកត្តាជីវភាពភាពអត់ការងារធ្វើរបស់ប្រជាជន និងការមកតាមគ្នា ដូចជាមានមេខ្យល់ ឬបងធំបងតូចជាដើម។ តែអ្វីដែលបានផ្លាស់ប្តូរ គឺកុមារទាំងអស់នោះ មានការយល់ដឹងពីសីលធម៏រស់នៅច្រើនជាងមុន"។

ជាចុងក្រោយ លោក ភិរុណ បានសំណូមពរដល់រដ្ឋាភិបាលអង្គការសង្គមស៊ីវិល និងសប្បុរសជននានា ទាំងក្នុង និងក្រៅប្រទេសសូមបន្តយកចិត្តទុកដាក់ លើកទឹកចិត្ត និងផ្គត់ផ្គង់ឧបត្ថម្ភបន្ថែមទៀតដល់ក្រុមកុមារអនាថាទាំងនោះ ដើម្បីឱ្យពួកគេមានអនាគតភ្លឺស្វាងគេចផុតពីគ្រោះអត់ឃ្លាន ការគំរាមកំហែងផ្សេងៗ និងដើម្បីឱ្យពួកគេមានឱកាសចូលរួមចំណែក ជាសរសរទ្រូងដ៏រឹងមាំក្នុងការអភិវឌ្ឍន៏ប្រទេសកម្ពុជាទៅថ្ងៃអនាគត ៕

***ដោយៈ ក្រុមគាំទ្រកុមារនៃបណ្តាញកុមារអ្នកតស៊ូមតិ***

# តំណាងក្រុមប្រឹក្សាឃុំ និងតំណាងកុមារ ក្នុងស្រុកសំរោង ទទួលការបណ្តុះបណ្តាលពីសិទ្ធិកុមារ

**តាកែវ:** សិក្ខាសាលាបណ្តុះបណ្តាលស្តីពីសិទ្ធិកុមារ និងការចូលរួមរបស់កុមារ សម្រាប់សមាជិកក្រុមប្រឹក្សាឃុំទទួលបន្ទុកកិច្ចការនារី និងកុមារ និងតំណាងកុមារមកពីឃុំនានា ក្នុងស្រុកសំរោង ខេត្តតាកែវ ត្រូវបានរៀបចំឡើងកាលពីថ្ងៃទី ១៩-២០ ខែសីហា នៅវិទ្យាល័យសម្តេចឪ ក្នុងឃុំសំរោង ស្រុកសំរោង ខេត្តតាកែវ ក្រោមការឧបត្ថម្ភរបស់អង្គការភ្លែន តាមរយៈគណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារ (គ.អ.ស.ក)។ គោលបំណងនៃសិក្ខាសាលានេះ គឺដើម្បីផ្តល់ចំណេះដឹងស្តីពីសិទ្ធិកុមារ និងការចូលរួមរបស់កុមារ ដល់សមាជិកក្រុមប្រឹក្សាឃុំទទួលបន្ទុកកិច្ចការនារី និងកុមារ និងតំណាងកុមារ ដើម្បីយកទៅផ្សព្វផ្សាយបន្ត ដល់សមាជិកក្រុមប្រឹក្សាឃុំ ប្រជាជន និងកុមារផ្សេងទៀតឱ្យយល់កាន់តែច្បាស់ពីសិទ្ធិកុមារ និងការចូលរួមរបស់កុមារ។ សមាជិកក្រុមប្រឹក្សាឃុំទទួលបន្ទុកកិច្ចការនារី និងកុមារ មកពីឃុំបឹងត្រាញ់ខាងជើង ឃុំរវៀង ឃុំលំចង់ ឃុំសិង្ហ ឃុំស្លា និងតំណាងកុមារមកពីអង្គការទស្សនៈពិភពលោក CCD និង VCAO នៃឃុំទាំង៥ សរុបទាំងអស់១៨នាក់ បានចូលរួមក្នុងសិក្ខាសាលានេះ។



លោកស្រី ជា ណារ៉េម (កណ្តាល) អភិបាលរងស្រុកសំរោង អញ្ជើញជាអធិបតីនៃសិក្ខាសាលា

លោកស្រី **ជា ណារ៉េម** អភិបាលរងស្រុកសំរោង បានមានប្រសាសន៍ក្នុងសុន្ទរកថាបើកសិក្ខាសាលានាឱកាសនោះថា *"សិក្ខាសាលារយៈពេលពីរថ្ងៃនេះ ជាឱកាសដ៏កំរមួយដែលតំណាងកុមារបានជួបជាមួយក្រុមប្រឹក្សាឃុំ ដូច្នេះក្មួយៗកុមារត្រូវប្រើប្រាស់ឱកាសនេះបញ្ចេញនូវអ្វីដែលជាតម្រូវការពិតរបស់កុមារ ដើម្បីឱ្យក្រុមប្រឹក្សាឃុំបានដឹង និងអាចឆ្លើយតបបានត្រឹមត្រូវ និងទាន់ពេល។ ចំណែកសមាជិកក្រុមប្រឹក្សាឃុំដែលទទួលបន្ទុកកិច្ចការនារី និងកុមារ ក៏ត្រូវព្យាយាមស្វែងយល់ពីតំរូវការ និងបញ្ហារបស់កុមារ ដើម្បីអាចជួយជ្រោមជ្រែងអភិវឌ្ឍ ពួកគេឱ្យក្លាយជាអ្នកបន្តវេនដ៏ល្អ សម្រាប់អភិវឌ្ឍន៍សហគមន៍យើងទាំងអស់គ្នា"*។

លោកស្រីអភិបាលរងស្រុក ក៏បានផ្តាំផ្ញើដល់តំណាងកុមារទាំងអស់ ដែលមានឱកាសបានចូលរួមក្នុងវគ្គសិក្សានេះ ឱ្យខិតខំប្រឹងប្រែងរៀនសូត្រ និងផ្សព្វផ្សាយនូវចំណេះដឹង និងបទពិសោធន៍ដែលទទួលបានរយៈពេលពីរថ្ងៃនេះ បន្តដល់កុមារផ្សេងទៀតដែលមិនបានចូលរួម។ លោកស្រីក៏បានក្រើនរំលឹកដល់តំណាងកុមារផងដែរថា *"សូមក្មួយៗខិតខំរៀនសូត្រ និងជៀសឱ្យឆ្ងាយពីគ្រឿងញៀន និងជំងឺអេដស៍"*។

លោក **ឆៃ ធូក** នាយកប្រតិបត្តិអង្គការស្នងការជាតិកម្ពុជាដើម្បីអភិវឌ្ឍន៍ ហៅកាត់ថា CCD ដែលសម្របសម្រួលឱ្យមានសិក្ខាសាលានេះឡើង បានមានប្រសាសន៍ថា *"សិក្ខាសាលាថ្ងៃនេះបានបង្ហាញឱ្យឃើញ ពីឧទាហរណ៍នៃកិច្ចសហប្រតិបត្តិការ ល្អរវាងរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលដែលជាដៃគូអភិវឌ្ឍន៍ដ៏សំខាន់របស់រដ្ឋាភិបាល លើកិច្ចការកុមារ និងការងារអភិវឌ្ឍន៍ផ្សេងទៀត"*។ លោក **ឆៃ ធូក** បានបន្តរំលឹកពីតំលៃនៃការចូលរួមរបស់កុមារ ក្នុងការជួយដល់អជ្ញាធរមូលដ្ឋានតាមដានលើបញ្ហានានាក្នុងសហគមន៍ និងថ្លែងសរសើរដល់ក្រុមប្រឹក្សាឃុំទាំងឡាយ ដែលបានផ្តល់ឱកាសឱ្យកុមារបានចូលរួមបញ្ចេញមតិយោបល់ និងចូលរួមក្នុងសកម្មភាពនានាកន្លងមករបស់ឃុំ ដែលជាការផ្តល់ឱកាសដ៏មានតម្លៃមួយ ក្នុងការបណ្តុះបណ្តាលពួកគេដែលអាចនឹងក្លាយជាមេឃុំ ឬថ្នាក់ដឹកនាំក្នុងគ្រួសារ សហគមន៍ និងប្រទេសជាតិទៅថ្ងៃអនាគត។

ចំណែកលោក **ឃុន ពិសី** ប្រធានផ្នែកព័ត៌មាន និងជាតំណាងឱ្យគណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារ (គ.អ.ស.ក) ក៏បានថ្លែងក្នុងចំណាប់អារម្មណ៍នាឱកាសនោះថា *"សិក្ខាសាលារយៈពេលពីរថ្ងៃនេះ នឹងផ្តល់ឱកាសដល់កុមារដែលជាម្ចាស់សិទ្ធិ និងតំណាងក្រុមប្រឹក្សាឃុំដែលជាអ្នកផ្តល់ ឬបំពេញសិទ្ធិអាចយល់គ្នាបានកាន់តែច្បាស់ ដែលអាចឈានទៅរកការធ្វើការរួមគ្នាកាន់តែយល់ចិត្តគ្នា និងទទួលបានផ្លែផ្កាច្រើនជាងមុន"*។ លោកបានបន្តទៀតថា សិក្ខាសាលាបណ្តុះបណ្តាលនេះ ក៏នឹងជួយឱ្យកុមារបានយល់ពីសិទ្ធិរបស់ខ្លួនកាន់តែច្បាស់ រីឯក្រុមប្រឹក្សាឃុំដែលជាមនុស្សចាស់ក៏អាចយល់បានច្បាស់ពីសិទ្ធិ និងតម្រូវការរបស់កុមារ ពិសេសស្ថានភាពរបស់កុមារបច្ចុប្បន្ន ដែលប្រាកដជាខុសគ្នាពីស្ថានភាពកុមារក្នុងជំនាន់ពួកគាត់។ ការជួបជុំគ្នាពីរថ្ងៃនេះ ក៏នឹងអាចជួយឱ្យក្រុមប្រឹក្សាឃុំបានយល់កាន់តែច្បាស់ពីតម្លៃនៃការចូលរួមរបស់កុមារ ដើម្បីឱ្យពួកគាត់ខិតខំបន្តការផ្តល់ឱកាស និងភាពងាយស្រួលកាន់តែច្រើនដល់កុមារក្នុងការចូលរួមលើកិច្ចការសំរេចចិត្តនានា ដែលទាក់ទងដល់ប្រយោជន៍របស់កុមារ ៕

ដោយឡែក កុមារី **ជាង សារ៉ី** អាយុ១៦ឆ្នាំ រៀនថ្នាក់ទី១១

នៅវិទ្យាល័យប៊ុន រ៉ានី-ហ៊ុនសែន ភ្នំជីសូរ ដែលជាអ្នកសម្របសម្រួលម្នាក់សម្រាប់សិក្ខាសាលានេះ បានបង្ហាញពីចំណាប់អារម្មណ៍ថា *"ខ្ញុំធ្លាប់រៀន និងសម្របសម្រួលសិក្ខាសាលាស្តីពីសិទ្ធិកុមារ និងការចូលរួមរបស់កុមារនេះ ច្រើនដងហើយ ប៉ុន្តែនេះជាលើកទី១ ដែលខ្ញុំត្រូវសម្របសម្រួលសិក្ខាសាលា ដែលមានសមាជិកក្រុមប្រឹក្សឃុំដែលជាមនុស្សចាស់ចូលរួម"*។ ប្អូនស្រីបានបន្តទាំងទឹកមុខរីករាយថា *"ដំបូងរាងភ័យបន្តិច ព្រោះខ្លាចប្រើពាក្យសំដីពុំសមរម្យជាមួយក្រុមប្រឹក្សាឃុំប៉ុន្តែយូរៗទៅធម្មតាវិញ ដោយសារពួកគាត់ជួយជ្រោមជ្រែង និងបង្កភាពស្និទស្នាលដូចជាកូនក្មួយរបស់ពួកគាត់។ ខ្ញុំសប្បាយរីករាយ និងមានមោទនភាពណាស់ ដែលមានឱកាសបានសម្របសម្រួលសិក្ខាសាលាដល់ក្រុមប្រឹក្សាឃុំបែបនេះ"*។ ប្អូនស្រីបានបន្តថា នេះជាឱកាសដ៏ល្អមួយដែលប្អូនអាចចែករំលែក ក៏ដូចជាទទួលបាននូវចំណេះដឹង និងបទពិសោធន៍ ពីអ្នកចូលរួមដែលមានទាំងកុមារ និងមនុស្សចាស់។ ប្អូននឹងអាចពង្រឹងសមត្ថភាពបន្ថែមទៀត តាមរយៈមតិរិះគន់កែលំអរបស់អ្នកចូលរួម និងការសិក្សាសង្កេតពីវិធីសាស្ត្រសម្របសម្រួលរបស់លោក **សុន ពេញ** ដែលជាមន្ត្រីជាន់ខ្ពស់ទទួលបន្ទុកការចូលរួមរបស់កុមារ របស់ គ.អ.ស.ក និងដែលជាអ្នកសម្របសម្រួលបង្គោលម្នាក់សម្រាប់សិក្ខាសាលានេះ។

ប្អូនស្រីដែលបានស្ម័គ្រចិត្តមកសម្របសម្រួលសិក្ខាសាលានេះ ដោយពុំទទួលបានប្រាក់កំរៃអ្វីនោះ យល់ឃើញពីតម្លៃដ៏ធំធេដែលប្អូនទទួលបានពីការងារសម្របសម្រួលនេះជាជាងប្រាក់កំរៃបន្តិចបន្តួច។ សាវរី បានបញ្ជាក់ថា *"បើទោះជាពុំទទួលបានថវិកា តែវាបានផ្តល់ប្រយោជន៏ដល់ខ្ញុំទៅថ្ងៃអនាគត។ ខ្ញុំអាចពង្រឹងភាពក្លាហានក្នុងការសម្របសម្រួល បានរៀនសូត្រពីវិធីសាស្ត្រសម្របសម្រួលល្អៗពីបងពេញបានយល់កាន់តែច្បាស់ពីសិទ្ធិកុមារនិងការចូលរួមរបស់កុមារជាពិសេសជំហានទាំង៨ នៃការចូលរួមរបស់កុមារ និងទទួលបានចំណេះដឹង និងបទពិសោធន៏ ជាច្រើនទៀតពីអ្នកចូលរួម"*។


តំណាងកុមារឡើងធ្វើបទបង្ហាញលើលទ្ធផលនៃកិច្ចការពិភាក្សាជាក្រុម

ប្អូនស្រីយល់ឃើញទៀតថា ប្រយោជន៏ទទួលបានពីសិក្ខាសាលានេះ ពុំមែនមានសម្រាប់តែរូបប្អូនផ្ទាល់ប៉ុណ្ណោះទេ គឺមានដល់គ្រួសារ និងសហគមន៏របស់ប្អូនទៀតផង។ *"ខ្ញុំនឹងចែករំលែកចំណេះដឹងពីសិទ្ធិកុមារ ពីបញ្ហាបច្ចុប្បន្នរបស់កុមារ ពីកលល្បិចរបស់មនុស្សចាស់ពីមធ្យោបាយការពារកុមារ ដល់ប្អូនៗ ឪពុកម្តាយរបស់ខ្ញុំ និងចាស់ៗក្នុងភូមិដែលជំនាន់ពួកគាត់ពុំធ្លាប់បានស្គាល់ ឬយល់ពីសិទ្ធិកុមារ និងការចូលរួមរបស់កុមារ"*។

សិក្ខាកាមម្នាក់ គឺលោកស្រី **ឈុន សាវ៉េត** អាយុ ៥៣ឆ្នាំ ជាសមាជិកក្រុមប្រឹក្សាឃុំបឹងត្រាញ់ខាងជើង ទទួលបន្ទុកកិច្ចការនារី និងកុមារ មានការពេញចិត្តយ៉ាងខ្លាំងចំពោះសិក្ខាសាលារយៈពេលពីរថ្ងៃនេះ ព្រោះសិក្ខាសាលានេះនឹងជួយរួមចំណែកជួយកុមារឱ្យមានការអភិវឌ្ឍន៍ជឿនលឿនទៅថ្ងៃមុខ។ លោកស្រីកាន់តែសប្បាយចិត្ត នៅពេលឃើញតំណាងកុមារមកពីឃុំនានាដែលចូលរៀនក្នុងសិក្ខាសាលានេះដែរ មានការខិតខំយកចិត្តទុកដាក់រៀនសូត្រ មិនខ្ជិលច្រអូស លេងសើចផ្តេសផ្តាស និងក្លាហានហ៊ានឡើងសម្របសម្រួល ដែលបង្ហាញឱ្យឃើញពីភាពចាស់ទុំ សាកសមជាតំណាង និងគំរូដល់កុមារផ្សេងទៀត។


ការពិភាក្សាជាក្រុមដែលកុមារ និងក្រុមប្រឹក្សាឃុំ
ជជែកផ្លាស់ប្តូរយោបល់គ្នា

លោកស្រី **ជា សារឿន** អាយុ៦០ឆ្នាំ ជាសមាជិកក្រុមប្រឹក្សាឃុំរវៀង ទទួលបន្ទុកកិច្ចការនារី និងកុមារ ដែលបានចូលរួមសិក្ខាសាលានេះដែរ បានមានប្រសាសន៍ថា "មករៀនវគ្គនេះ ខ្ញុំមានអារម្មណ៍សប្បាយ ជាងរៀនជាមួយអង្គការផ្សេងទៀតកន្លងមក។ ព្រោះបរិយា-កាសសិក្សាជាមួយកុមារ មានភាពទន់ភ្លន់ រីករាយ និងដោយមានបច្ចេកទេសសម្របសម្រួលដ៏ប៉ិនប្រសប់របស់លោកគ្រូផង"។ ជាមួយការសិក្សានេះ លោកស្រីបានមើលឃើញពីការរីកចំរើនលើចំណេះដឹង និងការយល់ដឹងពីព្រឹត្តិការណ៍សង្គមរបស់កុមារ ដែលធ្វើឱ្យលោកស្រីកាន់តែមានជំនឿចិត្តលើសមត្ថភាពរបស់ក្មេងជំនាន់ក្រោយ។ "បន្ទាប់ពីសិក្ខាសាលានេះ ខ្ញុំមានជំនឿចិត្តលើសមត្ថភាពកុមាររហូត៨០% ហើយខ្ញុំនឹងខិតខំឆ្លើយតបតាមតំរូវការរបស់ពួកគេ នូវអ្វីដែលខ្ញុំអាចឆ្លើយបាន បើកិច្ចការណាដែលខ្ញុំឆ្លើយតបមិនបាន ខ្ញុំនឹងស្នើទៅថ្នាក់លើដើម្បីឱ្យជួយ"។ លោកស្រីក៏បានសំណូមពរឱ្យអង្គការ បន្តវគ្គបណ្តុះបណ្តាលបន្ថែមទៀតដល់កុមារ និងក្រុមប្រឹក្សាឃុំ ដើម្បីឱ្យពួកគេកាន់តែមានការយល់ដឹងច្រើនលើសិទ្ធិកុមារ។

ចំណែក កុមារា **សឹម រ៉ា** អាយុ ១៧ឆ្នាំ រៀនថ្នាក់ទី១២ នៅវិទ្យាល័យសម្តេចឪ ជាសមាជិកក្លឹបអង្គក្លី របស់អង្គការ CCD និងជាសិក្ខាកាមក្នុងសិក្ខាសាលានេះដែរ យល់ឃើញថា "សិក្ខាសាលានេះ

ជាសិក្ខាសាលាទី១ ដែលខ្ញុំបានចូលរួម។ សិក្ខាសាលានេះបានធ្វើឱ្យខ្ញុំក្លាហាន ហ៊ាននិយាយ និងហ៊ានឡើងក្ដារយៀនធ្វើបទបង្ហាញលើលទ្ធផលនៃការពិភាក្សាជាក្រុម ដែលពីមុនខ្ញុំខ្លាច មិនហ៊ាននិយាយដូចថ្ងៃនេះទេ”។ ប្អូនប្រុសបន្តទៀតថា សិក្ខាសាលានេះក៏ជួយឱ្យប្អូនបានយល់ច្រើនពីបញ្ហារបស់កុមារ និងអនុសញ្ញាស្តីពីសិទ្ធិកុមារ ជាពិសេសបានដឹងពីប្រវត្តិរបស់អនុសញ្ញា អនុសញ្ញានេះមានប៉ុន្មានមាត្រា និងយល់ពីវិធីសាស្ត្រសម្របសម្រួលបែបសប្បាយៗ។ “ខ្ញុំពិតជាចង់រៀនវគ្គនេះបន្តទៀតណាស់” ប្អូនប្រុសនិយាយទាំងទឹកមុខរំភើបរីករាយ។

ប្អូនប្រុស **សឹម រ៉ា** បានឱ្យដឹងទៀតថា “ពីមុន ខ្ញុំអត់ហ៊ាននិយាយជាមួយក្រុមប្រឹក្សាឃុំទេ ប៉ុន្តែតាមរយៈការរៀនពីរថ្ងៃនេះខ្ញុំហ៊ាននិយាយជាមួយពួកគាត់ ព្រោះពួកគាត់ផ្តល់ឱកាស និងលើកទឹកចិត្តខ្ញុំឱ្យប្រឹងប្រែងរៀនសូត្រ។ ហើយគាត់ប្រាប់ខ្ញុំថា ក្មួយកុំខ្លាច ឥឡូវគេគោរពសិទ្ធិកុមារណាស់ ឱ្យតែយើងជាកុមារល្អ មិនដើរលេងផ្តេសផ្តាស”។ សិក្ខាសាលានេះមិនត្រឹមតែជួយឱ្យប្អូន និងក្រុមប្រឹក្សាឃុំបានយល់ចិត្តគ្នាប៉ុណ្ណោះទេ គឺថែមទាំងលើកទឹកចិត្តប្អូនឱ្យបន្តចូលរួមឱ្យបានខ្លាំងក្លាទៀតផង។ “ពួកគាត់ (ក្រុមប្រឹក្សាឃុំ) បានណែនាំខ្ញុំ និងកុមារផ្សេងទៀត ដូចជាពេលឡើងធ្វើបទបង្ហាញ ត្រូវណែនាំឈ្មោះជាមុនសិន”។ តំណាងក្រុមប្រឹក្សាឃុំ ក៏បានណែនាំប្អូន និងតំណាងកុមារផ្សេងទៀត ពេលលើកបញ្ហាកុមារក្នុងសហគមន៍ ដើម្បីស្នើឱ្យមានអន្តរាគមន៍ពីក្រុមប្រឹក្សាឃុំ ត្រូវមានព័ត៌មាន ឬភ័ស្តុតាងឱ្យបានច្បាស់លាស់។ ពួកគាត់ (ក្រុមប្រឹក្សាឃុំ) ក៏បានណែនាំតំណាងកុមារឱ្យរៀបចំជារបាយការណ៍រៀបរាប់ពីបញ្ហានិមួយៗដាក់ជូនទៅ ក្រុមប្រឹក្សាឃុំ ជៀសវាងឡើងរាយការណ៍ផ្ទាល់មាត់ ដែលអាចបង្កអសុវត្ថិភាពដល់ខ្លួនពេលជនល្មើសដឹង។

ចំណែក លោក ស៊ុន ពេញ មន្ត្រីជាន់ខ្ពស់ទទួលបន្ទុកការចូលរួមរបស់កុមារ និងជាអ្នកសម្របសម្រួលបង្គោលម្នាក់ក្នុងសិក្ខាសាលានេះ បានបង្ហាញពីចំណាប់អារម្មណ៍របស់ខ្លួនថា *“ខ្ញុំមានការសប្បាយចិត្តខ្លាំងណាស់ នៅពេលឃើញតំណាងក្រុមប្រឹក្សាឃុំ និងតំណាងកុមារ ជជែកពិភាក្សាគ្នាយ៉ាងជិតស្និទ ក្នុងពេលពិភាក្សាជាក្រុម ។ វាជាទិដ្ឋភាពមួយដែលកម្របានជួបប្រទះ”*។ លោកបានបន្តថា *“មនុស្សចាស់ និងកុមារ កាន់តែខិតជិតគ្នា ពួកគេលែងនៅក្នុងភពពីរដាច់ពីគ្នាទៀតហើយ”*។

លោក **នួន ហ៊ុន** អាយុ ៥៤ឆ្នាំ ជាសមាជិកក្រុមប្រឹក្សាឃុំសឹង្ហ ដែលចូលរួមវគ្គពីរថ្ងៃនេះដែរ មានចំណាប់អារម្មណ៍ថា “វាជាឱកាសល្អដែលបានចូលរៀនជាមួយកុមារ ជួបជាមួយកុមារផ្ទាល់។ មនុស្សចាស់មិនមែនធ្វើត្រូវគ្រប់រឿងនោះទេ។ ក្មេងៗអាចមើលឃើញចំណុចខ្សោយរបស់មនុស្សចាស់ គេអាចជួយកែលំអរយើង ហើយខ្ញុំប្រាកដជាទទួលយកមតិរិះគន់ស្ថាបនារបស់ពួកគេ”។

សិក្ខាសាលារយៈពេលពីរថ្ងៃនេះ ក៏មានកំណត់ផែនការសកម្មភាព ដើម្បីផ្សព្វផ្សាយបន្តដល់ក្រុមប្រឹក្សាឃុំ ប្រជាជន និងកុមារតាមភូមិ និងឃុំផ្សេងទៀតផងដែរ។

គណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារ ដោយមានការឧបត្ថម្ភថវិកាពីអង្គការភ្លែន ក៏បានរៀបចំសិក្ខាសាលាស្រដៀងគ្នានេះនៅតាមឃុំ ស្រុក សង្កាត់ ខណ្ឌផ្សេងៗទៀតនៅ ១១ រាជធានី-ខេត្ត រួមមាន: ខេត្តព្រៃវែង កណ្តាល ស្វាយរៀង តាកែវ ពោធិសាត់ ព្រះសីហនុ រតនគិរី បាត់ដំបង សៀមរាប កំពង់ចាម និងរាជធានីភ្នំពេញ ៕

***ដោយៈ ពិសី***

# កុមារនិង យុវជនកម្ពុជាចូលរួមវេទិកាយុវជនមេគង្គនៅថៃ



វេទិកាយុជនមេគង្គកម្ពុជាស្តីពីការជួញដូរមនុស្ស និងការធ្វើចំណាកស្រុក(MYF)បានចាប់ផ្តើមប្រារព្ធធ្វើឡើងនៅទីក្រុង បាងកកពីថ្ងៃទី២៤ ដល់ ២៩ ខែតុលាដោយមាន-ការចូលរួមពីប្រតិភូកុមារ និងយុវជន៣០ រូបមកពីប្រទេសចំនួន៦នៃមហាអនុតំបន់ទន្លេមេគង្គ។

រដ្ឋាភិបាលថៃបានទទួលធ្វើជាម្ចាស់ផ្ទះនៃវេទិកានេះ និងមានការរួមសហការពីអង្គការពលកម្មអន្តរជាតិ (ILO) អង្គការសង្គ្រោះកុមារអង់គ្លេស (SC-UK) គម្រោងអន្តរស្ថាប័នរបស់អង្គការសហប្រជាជាតិស្តីពីការជួញដូរមនុស្ស (UNIAP) និងអង្គការទស្សនៈពិភពលោក។

លោក **ប្រែអាន ជុងវិវ៉ាតាណាផន** មន្ត្រីសម្របសម្រួលព័ត៌មានកម្មវិធីអន្តរព្រំដែនប្រចាំតំបន់ថ្លែងថា: វេទិកានេះនិងផ្តល់ឱកាសដល់ប្រតិភូចែករំលែកគំនិតចំណេះដឹង និងអនុសាសន៍គ្នាទៅវិញទៅមក និងបង្កើតកិច្ចពិភាក្សាផ្ទាល់ជាមួយមន្ត្រីរដ្ឋាភិបាលស្តីពីមធ្យោបាយជួយសង្គ្រោះកុមារពីការជួញដូរមនុស្ស ដែលពួកគេធ្លាប់មានបទពិសោធន៍។

លោក **ទី សុវណ្ណារី** នាយកកម្មវិធីរបស់អង្គការសង្គ្រោះកុមារនៅកម្ពុជាដែលចូលរួមក្នុងនាមជាអ្នកសម្របសម្រួលកុមារ និងអ្នកបកប្រែផ្ទាល់មាត់មានប្រសាសន៍ថា: វាជាបញ្ហារសើប ហើយកិច្ចការ

ប្រជុំប្រចាំតំបន់ដែលមកពី ៦ ប្រទេសនេះ និងផ្តល់ឱកាសពួកគេផ្លាស់ប្តូរបទពិសោធន៍ និងចំណេះដឹងពាក់ពន្ធ័នឹងបញ្ហាជួញដូរមនុស្សពីប្រទេសនីមួយៗ ហើយនិងបង្ហាញពីអនុសាសន៍ ដើម្បីប្រមូលយកទៅបង្ហាញតំណាងរដ្ឋាភិបាលធ្វើការពិចារណា ដើម្បីស្វែងរកវិធីដោះស្រាយបញ្ហាទាំងនេះ ។

លោក សុវណ្ណារី មានប្រសាសន៍អំពាវនាវអោយមានសិក្ខាសាលាបែបសិល្បៈដើម្បីទាក់ទាញប្រតិភូកុមារ និងយុវជនតាមរយៈការគូសរូប ការពាក់ស្រោមមុខ និងការសម្តែងដែលធ្វើអោយពួកគេរីករាយ។

លោកបានគូសបញ្ជាក់ថាៈ យើងពិតជាគាំទ្រ និងលើកតម្កើងការចូលរួមពីកុមារ និងយុវជនក្នុងគោលបំណងធ្វើអោយប្រសើរឡើងនូវសិទ្ធិកុមារ មិនត្រឹមតែការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទទេ តែថែមទាំងការអប់រំ និងការបំពានពលកម្មកុមារផងដែរ ។

ប្រតិភូកុមារ និងយុវជនមកពីប្រទេសកម្ពុជា ៥រូបដែលជ្រើសរើសអោយទៅចូលរួមក្នុងវេទិកានេះ បានអមដំណើរដោយថ្នាក់ដឹកនាំ២រូបមកពីអង្គការសង្គ្រោះកុមារ និងអង្គការទស្សនពិភពលោក។

យុវជន **គង់ សុវណ្ណដេត** វ័យ ១៨ឆ្នាំជាប្រតិភូយុវជនមកពីខេត្តស្វាយរៀងប្រធានបណ្តាញកុមារអ្នកតស៊ូមតិបានថ្លែងថា ខ្ញុំមានអារម្មណ៍រំភើបខ្លាំងណាស់ និងជាឱកាសល្អមួយដែលខ្ញុំមិននឹកស្រមៃថាបានចូលរួមជាមួយយុវជនពីប្រទេសជា ច្រើនហើយអោយខ្ញុំទទួលបទពិសោធន៍ និងចំណេះដឹងកាន់តែច្រើនថែមទៀត ។

សុវណ្ណដេត តាំងចិត្តថា និងលើកតំកើងរួចរំលែកចំណេះដឹងទៅដល់សមាជិករបស់ខ្លួននៅតាមរាជធានី-ខេត្តចំនួន ១១ដែលមានជាង ២០០ក្លឹប ក៏ដូចជាចែកទៅដល់កុមារនៅក្នុងសហគមន៍ដើម្បីឱ្យពួកគេមានឱកាសដូចយុវជនដទៃ នឹងអាចជួយឱ្យជីវិតប្រសើរឡើងក្នុងភាពវៃឆ្លាត និងក្លាហាន។

យុវតី **កែវ បញ្ញា** អាយុ ១៩ឆ្នាំមកពីខេត្តកណ្តាលថ្លែងថាៈ ជាពលរដ្ឋមួយរូប ខ្ញុំមានកាតព្វកិច្ចចូលរួមការពារសុវត្ថិភាពកុមាររងគ្រោះទន់ខ្សោយពីអំពើជួញដូរមនុស្ស និងលើកតម្កើងបទពិសោធន៍របស់ខ្ញុំ ៕

*ដកស្រង់ពីកាសែត ភ្នំពេញប៉ុស្តិ៍*

# តំណាងកុមារ និងយុវជនកម្ពុជាចូលរួមវេទិកាកុមារអាស៊ាន និងសិក្ខាសាលាថ្នាក់តំបន់ស្តីពីការលើកកំពស់ និងគាំទ្រការចូលរួមរបស់កុមារ និងយុវជនក្នុងអាស៊ាន នៅប្រទេសហ្វីលីពីន


វេទិកាកុមារអាស៊ាន


សិក្ខាសាលាថ្នាក់តំបន់ស្តីពី ការចូលរួមរបស់កុមារ និងយុវជន

**ហ្វីលីពីនៈ** កុមារកម្ពុជា ៣ រូប ក្នុងនោះមានកុមារពិការភ្នែក ១ រូប ត្រូវបានជ្រើសរើសឱ្យទៅចូលរួមជាតំណាងកុមារកម្ពុជាក្នុង វេទិកាកុមារអាស៊ាន កាលពីថ្ងៃទី ១៩-២៣ ខែតុលា ឆ្នាំ២០១០។ កុមារា **និច ឌីប៉ូល** អាយុ ១៦ ឆ្នាំ ជាសិស្ស នៅរាជធានីភ្នំពេញ កុមារា **ស៊ុន ប៊ូរី** អាយុ ១៧ ឆ្នាំ ជាកុមារពិការភ្នែក មកពីអង្គការគ្រួសារថ្មី កុមារី **សឿន សាឡែន** អាយុ ១៣ ឆ្នាំ ជាកុមារមកពីអង្គការ Plan ខេត្តសៀមរាប ត្រូវបានជ្រើសរើសតាមរយៈការសម្ភាសន៍ និងការពិនិត្យលើលក្ខខណ្ឌកំណត់មួយចំនួន ដែលកំណត់ដោយអ្នករៀបចំវេទិកានៅប្រទេសហ្វីលីពីន សម្រាប់ជាតំណាងកុមារកម្ពុជា ចូលរួមក្នុងវេទិកាកុមារអាស៊ាន ដែលមានតំណាងកុមារមកពីប្រទេសនានាក្នុងសមាគមអាស៊ានចូលរួម។ លទ្ធផលសំខាន់ៗ នៃវេទិកាកុមារអាស៊ាននេះរួមមាន :

- បានប្រកាសឱ្យប្រើប្រាស់ Website កុមារអាស៊ានជាផ្លូវការ។ Web Site នោះគឺ www.aseanchildrensforum.org។ ទន្ទឹមនឹងនេះដែរ អ្នកបច្ចេកទេសបានធ្វើការបង្ហាញអំពីរបៀបប្រើប្រាស់ដើម្បីមើលព័ត៏មាន និងការបញ្ចូលព័ត៏មានពាក់ព័ន្ធនឹងប្រទេសនីមួយៗ។
- តំណាងកុមារ និងអ្នកមើលថែកុមារបានចែកជា ៥ក្រុម ដើម្បីធ្វើ

ទស្សនៈកិច្ចសិក្សា។ ក្រុមទាំង៥ នោះបានធ្វើទស្សនៈកិច្ចសិក្សានៅកន្លែងផ្សេងៗពីគ្នាទៅតាមប្រធានបទ។ ប្រធានទាំងនោះផ្តោតទៅលើ ការចូលរួមរបស់កុមារ ពលកម្មកុមារ កុមារពិការ កុមារទទួលរងផលប៉ះពាល់ដោយសារមេរោគអេដស៍/ជំងឺអេដស៍ និងការប្រើប្រាស់ Internet (កម្ពុជាបានចូលរួម២ក្រុម គឺកុមារពិការ និងការប្រើប្រាស់ Internet)។ ការធ្វើទស្សនៈកិច្ចសិក្សាគឺដើម្បីឱ្យកុមារស្វែងយល់អំពីបញ្ហាជាក់ស្តែងដែលកុមារកំពុងជួបប្រទះ និងមានជាគំនិត ដើម្បីដាក់បញ្ចូលក្នុងសេចក្តីថ្លែងការណ៍រួមមួយរបស់កុមារអាស៊ាន។ ទន្ទឹមនឹងនេះដែរសេចក្តីថ្លែងការណ៍រួមនេះនឹងដាក់ជូនកិច្ចប្រជុំអាស៊ានថ្នាក់រដ្ឋមន្ត្រី ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី ២៣-២៥ ខែ វិច្ឆិកា ឆ្នាំ២០១០ នៅប្រទេសប្រុយណេ។ (សេចក្តីព្រាងសេចក្តីថ្លែងការណ៍ អ្នករៀបចំនឹងផ្ញើមកតាមក្រោយបន្ទាប់ពីបានពិនិត្យ និង កែសម្រួលត្រឹមត្រូវ)។

- ជាមួយគ្នានេះដែរ វេទិកាកុមារអាស៊ានបានអំពាវនាវស្នើសុំដល់រដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ទាំងអស់មេត្តា ពិនិត្យមើលលទ្ធភាពគាំទ្រឧបត្ថម្ភឱ្យតំណាងកុមារ(យ៉ាងហោចណាស់ ០១នាក់) បានចូលរួមក្នុងកិច្ចប្រជុំ អាស៊ានថ្នាក់រដ្ឋមន្ត្រីនោះផង។ ព្រោះកិច្ចប្រជុំអាស៊ានថ្នាក់រដ្ឋមន្ត្រី តំណាងកុមារនឹងផ្ញើសេចក្តីថ្លែងការណ៍រួមដែលបានរៀបចំនៅហ្វីលីពីន។

ក្នុងរយៈពេលជាមួយគ្នានេះដែរ យុវជន **បៀង រ៉ៃយ៉ា** អនុប្រធានក្រុមគាំទ្រកុមារនៃអគ្គលេខាធិការដ្ឋាន គ.អ.ស.ក និងកុមារី ឆាត់ ស្រីម៉ិច អនុប្រធានបណ្តាញកុមារអ្នកតស៊ូមតិ ១១ រាជធានី-ខេត្ត ក៏ត្រូវបានអញ្ជើញចូលរួមក្នុងសិក្ខាសាលាថ្នាក់តំបន់មួយ ដើម្បីលើកកំពស់ និងគាំទ្រការចូលរួមរបស់កុមារ និងយុវជនក្នុងអាស៊ានដែលក៏ត្រូវបានរៀបចំឡើងនៅប្រទេសហ្វីលីពីនដូចគ្នា។ សិក្ខាសាលាដែលមានតំណាងកុមារ និងយុវជនមកពីប្រទេសនានាក្នុងសមាគមអាស៊ានចូលរួមនេះ បានជជែកពិភាក្សាគ្នា ពីស្ថានភាពនៃការចូលរួមរបស់កុមារ និងយុវជននៅតាមប្រទេសអាស៊ាន ការចែករំលែកបទពិសោធន៍ពាក់ព័ន្ធនឹងការចូលរួមរបស់កុមារ និងយុវជនក្នុងកិច្ចការអភិវឌ្ឍន៍ប្រទេស និងការផ្លាស់ប្តូរវប្បធម៌ផងដែរ ៕

***ដោយៈ ពិសី***

## ការធ្វើបច្ចុប្បន្នកម្មលើ របាយការណ៍ស្រមោល ទាក់ទងទៅនឹង ការអនុវត្តន៍សិទ្ធិកុមារនៅកម្ពុជា

**ភ្នំពេញៈ** គណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារ (គ.អ.ស.ក) បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់មួយកាលពីថ្ងៃទី20ខែតុលានេះនៅសណ្ឋាគារភ្នំពេញ ដើម្បីពិភាក្សាឆ្លុះបញ្ចាំងអំពីភាពត្រឹមត្រូវនៃទស្សនៈរបស់អ្នកជំនាញ និងដើម្បីអោយអ្នកជំនាញផ្សេងៗទៀតចូលរួមផ្តល់យោបល់បន្ថែម (ឈរលើព្រឹត្តិការណ៍ពិតដែលបានកើតឡើង) និងដើម្បីវាយតម្លៃលើរបាយការណ៍ស្រមោលដើម្បីឆ្លុះបញ្ចាំងលើរបាយការណ៍របស់រាជរដ្ឋាភិបាលកម្ពុជា។




លោកម៉ាគីសអាក្សលែន (Makus Asklan) នាយកប្រចាំប្រទេសនៃអង្គការសង្គ្រោះកុមារបានមានប្រសាសន៍ថា របាយការណ៍របស់រដ្ឋាភិបាលបង្ហាញព័ត៌មានសំខាន់ៗឬក៏ការវិវត្តន៍លើការងារ ដែលធ្វើដោយស្ថាប័ន ប៉ុន្តែធ្វើជាលក្ខណៈទូទៅអំពីតួនាទីរបស់រាជរដ្ឋាភិបាល តែមិនបានផ្តោតទៅលើបរិបទនៃស្ថានភាពជាក់ស្តែងនៅក្នុងសង្គមទាំងអស់នោះទេ។ ដូច្នោះយើងទាមទារអោយមានការចូលរួមពីស្ថាប័នផ្សេងៗដើម្បីបញ្ចូលព័ត៌មានបន្ថែមទៀតទៅក្នុងរបាយការណ៍ដែលផ្ញើទៅទីក្រុងហ្សឺណែវ ដោយផ្តោតទៅលើស្ថានភាពជាទូទៅរបស់កុមារដូចជាអំពើហិង្សា ការកេងប្រវ័ញ្ចកម្លាំងពលកម្មកុមារ ការសិក្សាអប់រំរបស់កុមារ កង្វះខាតរបស់កុមារក្នុងការទទួលបាននូវសេវាផ្អែកព័ត៌មានជាដើម។

លោកស្រី **ឃឹម សុខារី** ប្រធានគណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារបានមានប្រសាសន៍ថា របាយការណ៍ស្រមោលនេះមិនមែនមានន័យថា ជារបាយការណ៍ប្រឆាំងទៅនឹងរាជរដ្ឋាភិបាលនោះទេ គឺជារបាយការណ៍ដែលយើងឆ្លុះបញ្ចាំងរវាងសកម្មភាពដែលយើងអនុវត្តលើអនុសញ្ញាសិទ្ធិកុមាររវាងគ្នាទៅវិញទៅមកថា រដ្ឋាភិបាលបានធ្វើអ្វីខ្លះហើយអង្គការក្រៅរដ្ឋាភិបាលយើងបានធ្វើអ្វីខ្លះ សម្រាប់ការងារទាក់ទងទៅនឹងសិទ្ធិកុមារនេះ។ ប៉ុន្តែការឆ្លុះបញ្ចាំងនេះទាក់ទងទៅនឹងដៃគូអភិវឌ្ឍន៍ក្នុងការលើកម្ពស់សិទ្ធិកុមារនៅក្នុងប្រទេសកម្ពុជា។

លោកស្រីបានបន្ថែមថា ក្នុងនាមអង្គការមិនមែនរដ្ឋាភិបាលយើងក៏ព្យាយាមឆ្លុះបញ្ចាំងទៅក្នុងរបាយការណ៍ស្រមោលនេះនូវ៣ចំណុចគឺៈ១-គម្លាតនៃសមត្ថភាពរបស់តួអង្គសម្ព័ន្ធសិទ្ធិក្នុងការអនុវត្តន៍អនុសញ្ញាសិទ្ធិកុមារ។ សម្ព័ន្ធសិទ្ធិដែលមានការពាក់ព័ន្ធគ្នានោះ គឺសំដៅទៅលើសាមីសិទ្ធិគឺជាកុមារផ្ទាល់ ហើយអ្នកផ្តល់សិទ្ធិគឺជាមាតា

បិតា និងអាណាព្យាបាលកុមារផ្ទាល់ ហើយអ្នកការពារសិទ្ធិគឺរាជរដ្ឋាភិបាល ដែលយើងកំពុងតែឆ្លុះបញ្ចាំងរវាងគ្នាក្នុងខណៈនេះ និងអ្នកពាក់ព័ន្ធសិទ្ធិនៅខាងក្រោមានដូចជាក្រុមហ៊ុន សង្គមសាសនាទាំងឡាយត្រូវតែសហការគ្នាក្នុងការអោយតម្លៃទៅលើការអនុវត្តន៍សិទ្ធិកុមារនេះ។ ២-ហេតុអ្វីបានជាយើងទាំងអស់គ្នាដែលជាសម្ព័ន្ធសិទ្ធិទាំងអស់នេះមានគម្លាតជាមួយគ្នា និង ៣-គឺយើងលើកជាដំណោះស្រាយក៏ដូចជាអនុសាសន៍ដល់តួអង្គសម្ព័ន្ធសិទ្ធិទាំងអស់នោះ។



បន្ទាប់ពីលោកចនវីហ្កែន (John Vijghen) ទីប្រឹក្សាឯករាជ្យបានបង្ហាញពីទិដ្ឋភាពទូទៅនៃរបាយការណ៍ស្រមោលនោះ សិក្ខាសាលាពិគ្រោះយោបល់នេះបានពីភាក្សាគ្នាតាមក្រុមនីមួយៗទៅលើប្រធានបទចំនួន៩ ក្នុងនោះមាន 1-ការចុះបញ្ជីកំណើតកុមារគៀសខ្លួន។ 2-សិទ្ធិចូលរួម ឬឱកាសទទួលបានព័ត៌មានសមស្រប ។ 3-កុមារដែលបានបាត់បង់បរិយាកាសគ្រួសារ សិទ្ធិរស់រានមានជីវិត និងការអភិវឌ្ឍន៍។4-មេរោគអេដស៍/ជំងឺអេដស៍ ថ្នាំញៀន សុខភាព។ 5-ការអប់រំ ការកំសាន្ត និងសកម្មភាពវប្បធម៌។ 6-ការកេងប្រវ័ញ្ចសេដ្ឋកិច្ច ការរំលោភបំពានលើកុមារ ការជួញដូរ។ 7-បញ្ហាស្ដុំកូន។ 8-កុមារពិការ។ 9-យុត្តិធម៌អនីតិជន។

សិក្ខាសាលាពិគ្រោះយោបល់នេះបានផ្ដល់នូវអនុសាសន៍មួយចំនួនលើរបាយការណ៍ស្រមោលរបស់អង្គការមិនមែនរដ្ឋាភិបាលដើម្បី ស្ដីពីការអនុវត្តន៍អនុសញ្ញាអង្គការសហប្រជាជាតិស្ដីពីសិទ្ធិកុមារនៅកម្ពុជា ក៏ប៉ុន្តែអនុសាសន៍ទាំងនោះមិនមានអនុសាសន៍សម្រាប់កុមារនៅពន្ធនាគារ និងមីនបង្កប់ក្នុងដី និងគ្រោះថ្នាក់នោះទេ ៕

***អត្ថបទ រស្មីកម្ពុជា***

# ក្រុមកុមារ ពិគ្រោះយោបល់លើសេចក្ដីព្រាងរបាយការណ៍ ការអនុវត្តន៍ពិធីសារបន្ថែម០២ នៃអនុសញ្ញាសិទ្ធិកុមារ

**ភ្នំពេញៈ** ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារកាលពីថ្ងៃទី ១៥ ខែវិច្ឆិកា ឆ្នាំ២០១០ បានបើកវេទិកាកុមារថ្នាក់ជាតិស្ដីពីការពិគ្រោះយោបល់លើសេចក្ដីព្រាងរបាយការណ៍ការអនុវត្តន៍ពិធីសារបន្ថែម០២ នៃអនុសញ្ញាសិទ្ធិកុមារក្រោមអធិបតីភាពឯកឧត្ដម **ទីម ថូត** រដ្ឋលេខាធិការក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទាអនុប្រធានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារនិងជាប្រធានក្រុមការងារសរសេរសេចក្ដីព្រាងរបាយការណ៍។



លោកជំទាវ **ខៀវ ប៊ូរី** អគ្គលេខាធិការក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារបាននិយាយថា វេទិកានាពេលនេះរៀបចំឡើងក្នុងគោលបំណងផ្ដល់ឱកាសឱ្យក្មួយៗកុមារបានចូលរួមចំណែក ពិនិត្យលើសេចក្ដីព្រាងរបាយការណ៍ និងផ្ដល់មតិលើចំណុចរីកចំរើន និងចំណុចខ្វះខាតទាំងឡាយណាដែលមិនទាន់បានដាក់បញ្ចូលដើម្បីធានាសិទ្ធិចូលរួមរបស់កុមារលើដំណើរការរៀបចំសេចក្ដីព្រាងរបាយការណ៍។ ដោយឡែកបើក្មួយៗមានសំណូមពរថ្មីៗក៏ត្រូវតែលើកឡើងដែរ ដើម្បីជាគំនិតសំរាប់យើងទាំងអស់គ្នាពិចារណានិងគិតគូរទៅអនាគត។

លោកស្រី Souad AL-Hebshi ប្រធានកម្មវិធីកិច្ចការពារកុមារអង្គការយូនីសេហ្វបានសំដែងនូវការកោតសរសើរដល់រាជរដ្ឋាភិបាលកម្ពុជាអំពីភាពរីកចំរើនស្ដីពីការអនុវត្តន៍អនុសញ្ញាស្ដីពីសិទ្ធិកុមារចាប់តាំងពីកម្ពុជាបានផ្ដល់សច្ចាប័នលើអនុសញ្ញាស្ដីពីសិទ្ធិកុមារ និងលើពិធីសារបន្ថែម។

លោកស្រីបន្តថាការរីកចំរើនទាំងនេះមានការធ្វើអោយមានភាពសមស្របគ្នារវាងក្របខ័ណ្ឌច្បាប់សំខាន់ៗជាមួយនឹងអនុសញ្ញាស្ដីពីសិទ្ធិកុមារការបង្កើតនូវគោលនយោបាយផ្សេងៗនីតិវិធីនិងបទដ្ឋានអប្បបរមាស្ដីពីការថែទាំជំនួសកុមារយុត្តិធម៌កុមារ និងការការពារកុមារពីការកេងប្រវ័ញ្ចនិងការជួញដូរ។ការបង្កើនសមត្ថភាពរបស់មន្ត្រីសង្គមកិច្ចការអនុវត្តន៍ច្បាប់ និងមន្ត្រីយុត្តិធម៌ការប្រសើរឡើងនៃការការពារកុមារ និងសេវាសមាហរណកម្មនិងភាពអាចរកបាននូវប្រព័ន្ធទិន្នន័យចំពោះរឿងផ្សេងៗដែលពាក់ព័ន្ធនឹងកុមារ។

លោកស្រីបានបន្ថែមថា កត្តាជោគជ័យនៃការចូលរួមរបស់កុមារនៅក្នុងដំណើរការសរសេររបាយការណ៍គឺនៅពេលដែលយើង

ធានាបានថាកុមារត្រូវបានពិគ្រោះយោបល់និងអាចបញ្ចេញយោបល់តាមរយៈភាសារបស់គេផ្ទាល់ហើយធ្វើការពិភាក្សាដោយកុមារផ្ទាល់។

លោកស្រីបន្ថែមថា ការចូលរួមរបស់កុមារនឹងជួយធ្វើឱ្យប្រសើរឡើងនូវសេចក្តីព្រាងរបាយការណ៍ដោយផ្តល់នូវព័ត៌មានផ្សេងៗ និងវាយតំលៃលើរបាយការណ៍ថា តើរបាយការណ៍នេះឆ្លុះបញ្ចាំងពីអាទិភាពនៃតំរូវការរបស់កុមារដែរឬទេ។ អង្គការយូនីសេហ្វលើកទឹកចិត្តដល់រាជរដ្ឋាភិបាលកម្ពុជា និងសង្គមស៊ីវិលយកចិត្តទុកដាក់លើយោបល់របស់កុមារដោយអង្គការនឹងគាំទ្រដើម្បីធ្វើអោយរបាយការណ៍នេះមានគុណភាពខ្ពស់ដើម្បីជួយធានាអោយបានថាសិទ្ធិរបស់កុមារនៅកម្ពុជាត្រូវបានគោរព និងការពារ។

ឯកឧត្តម **ទឹម ថូត** បានមានប្រសាសន៍ថា គោលបំណងនៃវេទិកាកុមារថ្នាក់ជាតិនេះមាន២ គឺទី១-ដើម្បីអោយកុមារបានផ្តល់មតិលើសេចក្តីព្រាងរបាយការណ៍ ស្តីពីការអនុវត្តន៍ពិធីសារបន្ថែមនៃអនុសញ្ញាសិទ្ធិកុមារ ស្តីពីការចូលរួមរបស់កុមារនៅក្នុងជំលោះប្រដាប់អាវុធ និងការលក់កុមារការធ្វើពេស្យាកម្មកុមារនិងរូបភាពអាសអាភាសកុមារនិងទី២-ដើម្បីធានាសិទ្ធិចូលរួមរបស់កុមារលើដំណើរការរៀបចំសេចក្តីព្រាងរបាយការណ៍។

លោកបន្តថាការចូលរួមវេទិកានេះបញ្ជាក់អោយឃើញថាយើងទាំងអស់គ្នាខិតខំយកចិត្តទុកដាក់អនុវត្តសិទ្ធិចំបងទាំង ៤ របស់កុមារដែលក្នុងនោះមានទាំងសិទ្ធិបញ្ចេញទស្សនៈនិងការគោរពទស្សនៈរបស់កុមារផងដែរ ៕



***កាសែតកម្ពុជាថ្មី, ថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ២០១០***

# អ្នកជំនាញជួបពិភាក្សាលើសេចក្តីព្រាងច្បាប់ យុត្តិធម៌អនីតិជន

**ភ្នំពេញ:** សេចក្តីព្រាងច្បាប់យុត្តិធម៌អនីតិជន ដែលមាន១៥ជំពូក និង៨៦មាត្រា ដែលបានបង្កើតឡើង ដោយរដ្ឋាភិបាលកម្ពុជាត្រូវគេរំពឹងថា នឹងជួយការពារសិទ្ធិនិងអត្ថប្រយោជន៍របស់អនីតិជនប្រព្រឹត្តល្មើសនឹងច្បាប់ ពិសេសនឹងធានាលើអនីតិជន ដែលមានអាយុក្រោម ១៤ឆ្នាំ អោយរួចផុតពីការទទួលខុសត្រូវលើបទព្រហ្មទណ្ឌចំពោះករណីល្មើសច្បាប់របស់ពួកគេ។




ថ្លែងនៅក្នុងសិក្ខាសាលាថ្នាក់ជាតិស្តីពីការស្វែងរកមតិគាំទ្រលើសេចក្តីព្រាងច្បាប់យុត្តិធម៌អនីតិជន ដែលបានប្រព្រឹត្តទៅនៅសណ្ឋាគារណាហ្គាវើល កាលពីម្សិលមិញ ឯកឧត្តម **អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានបញ្ជាក់ថា សេចក្តីព្រាងច្បាប់នេះបានរៀបរៀងឡើង តាំងពីឆ្នាំ ២០០២ ដោយមានការចូលរួមប្រឹក្សាយោបល់ ពីអង្គការយូនីសេហ្វ និងអង្គការដៃគូ មួយចំនួនទៀតដែលធ្វើសកម្មភាពលើកស្ទួយសិទ្ធិ និងសុខុមាលភាពរបស់កុមារ។ លោកមានប្រសាសន៍ថា: *"សេចក្តីព្រាងច្បាប់យុត្តិធម៌ អនីតិជននេះគឺមានឧបករណ៍ សម្រាប់ការពារសិទ្ធិនិងផលប្រយោជន៍របស់កុមារនៅគ្រប់កាលៈទេសៈ និងគ្រប់ទីកន្លែងទៅតាមផ្លូវច្បាប់"*។

ឯកឧត្តម **អ៊ិត សំហេង** បានបញ្ជាក់ទៀតថា នេះជាលើដំបូងហើយ ដែលប្រទេសកម្ពុជា នឹងមានច្បាប់ដោយឡែកពិសេសមួយសម្រាប់កុមារដូចបណ្តាប្រទេសរីកចម្រើនជឿនលឿន លើពិភពលោកដែរ។

យោងតាមមាត្រាមួយចំនួន ដែលបានចែងក្នុងសេចក្តីព្រាងច្បាប់នេះ ដែលទទួលបានកាលពីម្សិលមិញបានគូសបញ្ជាក់ថា រាល់បទល្មើស ដែលបានប្រព្រឹត្តដោយកុមារដែលមានអាយុក្រោម ១៤ឆ្នាំ មន្ត្រីនគរបាលយុត្តិធម៌ មិនអាចចាប់ឃាត់ខ្លួន ឬបង្ខំអោយពួកគេទទួលខុសត្រូវព្រហ្មទណ្ឌឡើយ ប៉ុន្តែមន្ត្រីនគរបាលយុត្តិធម៌ អាចចាប់ឃាត់ខ្លួនចំពោះកុមារដែលមានអាយុពី ១៤ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ ក្នុងករណីពួកគេ បានប្រព្រឹត្តបទល្មើសបឋ្មឹម ឬឧក្រិដ្ឋជាក់ស្តែងប៉ុណ្ណោះ ឬក្នុងករណីមានដីកាបង្គាប់អោយនាំខ្លួនឬដីកាចាប់ខ្លួនពីអាជ្ញាធរតុលាការ។ (អនីតិជនប្រព្រឹត្តល្មើសនឹងច្បាប់ដែលមានអាយុក្រោម ១៤ឆ្នាំ មិនទទួលខុសត្រូវទោសព្រហ្មទណ្ឌទេ) នេះជាបទចែងក្នុងមាត្រា ៧ នៃសេចក្តីព្រាងច្បាប់នេះហើយក្នុងមាត្រា ១៤ បានសរសេរទៀតថា

(អនីតិជនប្រព្រឹត្តល្មើសនឹងច្បាប់ដែលមានអាយុក្រោម ១៤ឆ្នាំ ដែលជាប់សង្ស័យថា បានប្រព្រឹត្តបទល្មើស មន្ត្រីនគរបាលយុត្តិធម៌មិនត្រូវឃាត់ខ្លួនឡើយ។ ក្នុងករណីនេះ មន្ត្រីនគរបាលត្រូវប្រគល់អនីតិជននោះទៅអោយឪពុកម្តាយ ឬអ្នកអាណាព្យាបាលវិញ)។

លោកស្រី **យឹម សុខារី** ប្រធានគណៈកម្មាធិការប្រតិបត្តិនៃគណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារបានថ្លែងនៅក្នុងសិក្ខាសាលានេះថា កុមារពិតជាពុំទាន់មានសមត្ថភាពគិតពិចារណាត្រឹមត្រូវគ្រប់គ្រាន់នៅឡើយទេ ពួកគេអាចប្រឈមនូវបញ្ហាជាច្រើន និងអាចក្លាយជាជនល្មើស ឬរងគ្រោះដោយសារការសេពគប់មជ្ឈដ្ឋានមនុស្សខុស ការមិនយកចិត្តទុកដាក់ ពីសំណាក់ក្រុមគ្រួសារ និងសហគមន៍ ការធ្វើចំណាកស្រុក ការបែកបាក់ឪពុកម្តាយ ភាពក្រីក្រ អំពើហិង្សាក្នុងគ្រួសារ និងកង្វះការអប់រំ។ លោកស្រីបានបញ្ជាក់ថា: ព្រោះតែបញ្ហាក្រពះ កុមារមួយចំនួនគ្មានជម្រើសអ្វីផ្សេងក្រៅពីការប្រព្រឹត្តអំពើល្មើសនឹងច្បាប់ដូចជាការលួច ឆក់ និងឈានដល់អំពើប្លន់)។

ឯកឧត្តម **អ៊ិត សំហេង** មានប្រសាសន៍ថា បច្ចុប្បន្នកុមារទំនាស់នឹងច្បាប់កំពុងមានចំនួនកាន់តែច្រើនឡើង ពិសេសនៅរាជធានីភ្នំពេញ ហើយមួយចំនួនក្នុងចំណោមពួកគេ ត្រូវបានចាប់បញ្ជូនទៅកាន់មជ្ឈមណ្ឌលស្តាយុវនីតិសម្បទានៃក្រសួងសង្គមកិច្ច និងខ្លះទៀតត្រូវបានបញ្ជូនទៅដាក់ក្នុងពន្ធនាគារ។

ឯកឧត្តមក៏បានបញ្ជាក់ផងដែរថា ***“កន្លងមកកុមារមួយចំនួនត្រូវបានឃុំខ្លួនជាមួយមនុស្សពេញវ័យ ដែលការឃុំខ្លួនបែបនេះ ធ្វើឱ្យប៉ះពាល់ដល់សិទ្ធិកុមារក្នុងការទទួលបានការថែទាំសមស្រប”***។

ទោះជាបែបណាក៏ដោយ ការសម្រេចផ្តន្ទាទោស ឬការប្រកាសទណ្ឌកម្មព្រហ្មទណ្ឌ ទៅលើអនីតិជនល្មើសច្បាប់ ដែលមានអាយុពី ១៤ ឆ្នាំ ទៅក្រោម ១៨ ឆ្នាំ សេចក្តីព្រាងច្បាប់នេះ ក៏បានតម្រូវអោយតុលាការសាលាដំបូង និងតុលាការជាន់ខ្ពស់ពិនិត្យពិចារណាលើកាលៈទេសៈស្ថានភាព និងសតិបញ្ញាស្មារតីនៃជនជាប់ចោទដោយរួមបញ្ចូលទាំងកត្តាសម្រាលផ្សេងៗទៀតផងដែរ។ តុលាការសាលាដំបូង ឬជាន់ខ្ពស់អាចសម្រេចប្រគល់ទណ្ឌិតជាអនីតិជន ដែលត្រូវបានផ្តន្ទាទោសទៅអោយមណ្ឌលស្តារនីតិសម្បទារាជធានី-ខេត្ត ដែលយល់ឃើញថាសមស្រប។

ឯកឧត្តម **ហ៊ី សោភា** រដ្ឋលេខាធិការក្រសួងយុត្តធម៌បានថ្លែងបញ្ជាក់នៅក្នុងសិក្ខាសាលាថា ទោះជាយ៉ាងណាក៏ដោយក៏ការសម្រេចឃុំខ្លួនអនីតិជនគឺជាជម្រើសចុងក្រោយបំផុត ៕

***កាសែតភ្នំពេញប៉ុស្តិ៍ ថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ២០១០***

# ក្រុមការងារចម្រុះដើម្បីយុត្តិធម៌អនីតិជន



យន្តការប្រកបដោយប្រសិទ្ធភាពក្នុងការជម្រុញ និងគាំទ្រការ អនុវត្តច្បាប់ និងគោលការណ៍នីតិរដ្ឋ គឺផ្តើមចេញពីការសហការរួមគ្នារវាង អ្នកអនុវត្តច្បាប់ និងអ្នកធ្វើច្បាប់។ ផ្តើមចេញនូវចំនុចនេះ ក្រុមការងារអង្គការមិនមែនរដ្ឋាភិបាលដើម្បីយុត្តិធម៌កុមារ នៃគណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារ និងក្រុមការងារយុត្តិធម៌កុមារ នៃក្រសួងយុត្តិធម៌បានចុះកិច្ចព្រមព្រៀងធ្វើការរួមគ្នារវាងក្រុមទាំងពីរដោយបង្កើតជាក្រុមការងារចម្រុះដើម្បីយុត្តិធម៌អនីតិជន នៅខែ កញ្ញាឆ្នាំ ២០០៩ ក្នុងគោលបំណងពង្រឹងប្រព័ន្ធយុត្តិធម៌អនីតិជន។ក្រុមកាងារចម្រុះបានឯកភាពអនុវត្តលើផែនការប្រចាំឆ្នាំរួមគ្នា ការដាក់បញ្ហារួមគ្នាទាក់ ទងនឹងអនីតិជន ដើម្បីធ្វើការដោះស្រាយ។

ផ្តើមចេញពីគំនិតផ្តួចផ្តើមនេះក្រុមការងារចម្រុះបាន បោះឆ្នោតជ្រើសរើសប្រធាន១ រូប និងអនុប្រធាន ២រូប ក្នុងនោះមានឯកឧត្តម **អ៊ិត រ៉ាឌី** អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ ជាប្រធានក្រុមការងារ លោក **គង់ ឆាន** អគ្គនាយករងនៃនាយកដ្ឋានបច្ចេកទេស នៃក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា ជាអនុប្រធាន និងលោកស្រី **សម្បត្តិ សុគន្ធា** ប្រធានកម្មវិធីតស៊ូមតិនៃ អង្គការអេទ្រីឆាលកម្ពុជា ជាអនុប្រធាន ។

ខាងក្រោមនេះជាសកម្មភាពសំខាន់ៗ របស់ក្រុមការងារចំរុះក្នុងឆ្នាំ ២០១០ :

## កម្មវិធីវេទិកាពិភាក្សាតុមូលស្តីពីសិទ្ធិតាមផ្លូវច្បាប់របស់កុមារទំនាស់ នឹងច្បាប់ និងកម្មវិធីបង្វែរ





នៅថ្ងៃ ខែឧសភា ឆ្នាំ ២០១០ ក្រោមការជួយឧបត្ថមរបស់អង្គការយូនីសេហ្វ និងអង្គការអេវ្រីឆាលកម្ពុជា ក្រុមការងារចម្រុះបានធ្វើវេទិកាពិភាក្សាតុមូលនៅទូរទស្សន៍ជាតិកម្ពុជា និងតាមវិទ្យុក្រោមប្រធានបទ សិទ្ធិតាមផ្លូវច្បាប់របស់កុមារទំនាស់ នឹងច្បាប់ និងកម្មវិធីបង្វែរ ក្នុងគោលបំណងលើកកម្ពស់ការយល់ដឹងដល់សាធារណៈជនលើសិទ្ធិស្របច្បាប់របស់កុមារ ទំនាស់នឹងច្បាប់ ។

## សិក្ខាសាលាស្តីពីគំរោងសាកល្បងក្នុងការបង្កើតតុលាការកុមារ





នៅថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ២០១០ ក្រុមការងារចម្រុះដើម្បីយុត្តិធម៌អនីតិជន ក្រោមការជួយឧបត្ថម្ភពីអង្គការអេវ្រីឆាលកម្ពុជាបានធ្វើសិក្ខាសាលាមួយស្តីពីគំរោងសាកល្បងក្នុងការបង្កើតតុលាការកុមារនៅកម្ពុជា។ ជាលទ្ធផលនៃសិក្ខាសាលានេះយើងបាន សម្រេចរួមគ្នានឹងបង្កើតអោយមានតុលាការសាកល្បងនៅខេត្តព្រៃវែង ដោយមានការគាំទ្រ និងឯកភាពពីឯកឧត្តម **អង្គ វង្សវឌ្ឍានា** រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងលោកជំទាវ **ម៉ាហ្គារេដ អាដាំសិន** អគ្គរាជទូតអូស្ត្រាលីប្រចាំនៅកម្ពុជា ៕

# កុមាររស់នៅក្នុងសិប្បកម្មឡឥដ្ឋ ៧៥% ធ្វើការចាប់ពីអាយុក្រោម ១២ ឆ្នាំ

**រាជធានីភ្នំពេញ:** ពេលខ្ញុំកំពុងបោះដីចូលក្នុងម៉ាស៊ីន ដីវាស្ទះ អ៊ីចឹងខ្ញុំក៏ប្រឹងរុញវាចូល ហើយពេលនោះ ម៉ាស៊ីនបានស្រូបយកដៃខ្ញុំ។ ក្រោយពេលគ្រោះថ្នាក់ ខ្ញុំបានវិលត្រឡប់ទៅរស់នៅឯស្រុកកំណើតជាមួយឪពុក និងប្អូនប្រុសបីនាក់ទៀតរបស់ខ្ញុំ។ ខ្ញុំត្រូវមើលថែពួកគេទាំងអស់គ្នា ពីព្រោះឪពុករបស់ខ្ញុំមានបញ្ហាខ្សោយសតិអារម្មណ៍។ ខ្ញុំអស់សង្ឃឹមណាស់ ហើយក្តីស្រមៃរបស់ខ្ញុំក៏រលាយបាត់ផងដែរ ពីព្រោះខ្ញុំពិការ ហើយគ្មានចំណេះវិជ្ជាទៀត។ ខ្ញុំមិនដឹងថា ខ្ញុំត្រូវធ្វើអ្វីនោះទេក្រៅពីទៅឃ្វាលគោរាល់ថ្ងៃ។ ខ្ញុំឈប់រៀនតាំងពីថ្នាក់ទីមួយ មកម្ល៉េះ គឺមុនពេលដែលខ្ញុំទៅធ្វើការនៅឡឥដ្ឋ។ នេះជាសំដីរបស់ក្មេងប្រុសម្នាក់អាយុ១៦ឆ្នាំ ដែលពិការដៃខាងឆ្វេងនៅពេលគេធ្វើការនៅក្នុងឡឥដ្ឋ។

អង្គការលីកាដូសហការជាមួយអង្គការទស្សនៈពិភពលោកកម្ពុជាបានប្រារព្ធទិវាពិភពលោកប្រយុទ្ធប្រឆាំងនឹងពលកម្មកុមារ នៅថ្ងៃទី ១២ ខែមិថុនា ឆ្នាំ២០១០ តាមរយៈការហែរក្បួន និងការប្រគុំតន្ត្រីនៅក្នុងស្រុកសង្កែ ខេត្តបាត់ដំបង។ ព្រឹត្តការណ៍នេះមានគោលបំណងធ្វើអោយសាធារណជនយល់ ដឹងអំពីបញ្ហាពលកម្មកុមារ ជាពិសេសពលកម្មកុមារនៅសិប្បកម្មឡឥដ្ឋ។ ការប្រគុំតន្ត្រីនេះរួមមានកម្មវិធីសំដែង រឿងខ្លី ចំរៀងកំសាន្ត និងនាទីសំណើច។ ពិធីនេះមានគោលបំណងផ្សព្វផ្សាយអំពីទំរង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ និងផលប៉ះពាល់ចំពោះសុខាភាព សុវត្ថិភាព និងការសិក្សាអប់រំរបស់កុមារ។

នេះជាលើកទីពីរហើយដែលអង្គការលីកាដូ និងអង្គការទស្សនៈពិភពលោកកម្ពុជា បានរៀបចំពិធីជាសាធារណៈបែបនេះនៅខេត្តបាត់ដំបងដែលបានកំណត់យកសារសំខាន់ ខ្ញុំការពារកុមារចុះអ្នកវិញ? ព្រឹត្តិការណ៍នេះ ជាសកម្មភាពមួយនៃគំរោងក្រោមកិច្ចសហការរវាងអង្គការលីកាដូ និងអង្គការសទ្សនៈពិភពលោកកម្ពុជា ដើម្បីកាត់បន្ថយទំរង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារដែលមានចែងនៅក្នុងអនុសញ្ញារបស់អង្គការពលកម្មអន្តរជាតិ លេខ១៨២។ យោងតាមរបាយការណ៍ស្រាវជ្រាវរួមគ្នារវាងអង្គការលីកាដូ និងអង្គការទស្សនៈពិភពលោកកម្ពុជា នៅឆ្នាំ២០០៧ បានបង្ហាញថា មានកុមារចន្លោះពី ៤០០ ទៅ ៥០០នាក់ ធ្វើការនៅក្នុងសិប្បកម្មឡឥដ្ឋក្នុងខេត្តបាត់ដំបង នារដូវដែលមានតំរូវការពលកម្មខ្ពស់។

ប្រភេទការងារដែលកុមារតែងតែធ្វើនៅក្នុងឡឥដ្ឋដូចជា អូសរទេះដឹកឥដ្ឋ ជញ្ជូនឥដ្ឋចូល និងចេញពីឡ ជញ្ជូនឥដ្ឋដាក់ចូល និងចេញពីរទេះ ជញ្ជូនឥដ្ឋដាក់ឡាន និងហាលឥដ្ឋ។ កុមារមួយចំនួនធ្វើការជាអ្នកកាន់ម៉ាស៊ីនផលិតឥដ្ឋ និងជាអ្នកដុតភ្លើងឡឥដ្ឋជាដើម។ ពលកម្មកុមារត្រូវបានជួលអោយធ្វើការ ក្នុងលក្ខខណ្ឌការងារបីយ៉ាងសំខាន់រួមមាន ការងារម៉ៅការធ្វើការពេញម៉ោងរៀងរាល់ថ្ងៃ និងការងារមិនពេញម៉ោង ឬចុងសប្តាហ៍។ ទោះបីជាលក្ខខណ្ឌការងារនេះមិនល្អសំរាប់កុមារក៏ដោយម្ចាស់សិប្បកម្មឡឥដ្ឋ ជាច្រើនត្រូវគេ សង្ស័យថា នៅតែព្យាយាមជួលពលករកុមារអោយធ្វើការដដែល។ កុមារមួយចំនួនត្រូវបានឪពុកម្តាយរបស់ពួកគេបញ្ជូនអោយទៅធ្វើការនៅឡឥដ្ឋ។ ការជួលពលករកុមារអោយធ្វើការនៅក្នុងឡឥដ្ឋមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ការអភិវឌ្ឍរបស់កុមារ ជាពិសេសចំពោះសុខភាព និងការសិក្សាអប់រំរបស់ពួកគេ។

លោកស្រី **ណាលី ពីឡុក** នាយិកាអង្គការលីកាដូមានប្រសាសន៍ថា ឡឥដ្ឋជាកន្លែងការងារមួយដ៏អាក្រក់សំរាប់កុមារ។ វាមិនត្រឹមតែមានផលអវិជ្ជមានចំពោះការសិក្សា និងការអភិវឌ្ឍរបស់កុមារប៉ុណ្ណោះទេ ប៉ុន្តែវាថែមទាំងធ្វើអោយកុមារប្រឈមនឹងគ្រោះថ្នាក់ខ្ពស់រួមទាំងការស្លាប់ផងដែរ។

របាយការណ៍ស្រាវជ្រាវដដែលនៅបានរកឃើញថា ពលករកុមារដែលធ្វើការនៅតាម សិប្បកម្មឡឥដ្ឋ ចាប់ផ្តើមធ្វើការតាំងពីអាយុនៅតិចម្ល៉េះ ជាពិសេសកុមារដែលរស់នៅក្នុងសិប្បកម្មឡឥដ្ឋប្រមាណជា ៧៥ភាគរយ ចាប់ផ្តើមធ្វើការតាំងពីអាយុក្រោម ១២ ឆ្នាំ ហើយ ២៥.៧ ភាគរយទៀតចាប់ផ្តើមធ្វើការនៅអាយុចន្លោះពី ៦ទៅ ៨ឆ្នាំ។ ក្នុងចំណោមកុមារដែលមិនរស់នៅក្នុងសិប្បកម្មឡឥដ្ឋមានកុមារ២១.៨ ភាគរយ ចាប់ផ្តើមធ្វើការនៅ អាយុក្រោម ១២ឆ្នាំ ហើយ ៤៤.៦ ភាគរយ ចាប់ផ្តើមធ្វើការនៅអាយុចន្លោះពី ១២ ទៅ ១៤ឆ្នាំ និង ៣៣.៧ ភាគរយ ទៀតចាប់ផ្តើមធ្វើការនៅអាយុ១៥ឆ្នាំ។ កុមារដែលធ្វើការក្នុងឡឥដ្ឋភាគច្រើនមិនបានទៅសាលារៀនទេ។

លោកស្រី **ណាលី ពីឡុក** បានបន្ថែមថាទោះបីជាបញ្ហាកុមារបំរើការងារ នៅសិប្បកម្មឡឥដ្ឋត្រូវបានផ្សព្វផ្សាយក៏ដោយ ប៉ុន្តែបញ្ហានេះនៅតែបន្តកើតមានដល់បច្ចុប្បន្ន។ ពិតណាស់ វាពិតជាទាមទារអោយមានការផ្តល់ព័ត៌មាន និងការបណ្តុះបណ្តាលបន្ថែមដើម្បីឈានដល់ការលប់បំបាត់បញ្ហាទាំងនេះ ។

***អត្ថបទៈ កោះសន្តិភាព***

# ការរំលោភសេពសន្ថវៈកុមារ កើនឡើងក្នុងឆ្នាំ ២០១០



**ភ្នំពេញៈ** ក្រុមមន្ត្រីប៉ូលីសនិងអង្គការសង្គមស៊ីវិលបាននិយាយនៅថ្ងៃច័ន្ទនេះថា ប្រទេសកម្ពុជាត្រូវបង្កើតផែនការយុទ្ធសាស្ត្រថ្មីៗជាច្រើនទៀតសម្រាប់ជំរុញចលនាលើកកម្ពស់តម្លៃសីលធម៌សង្គម ការចាត់វិធានការបង្ក្រាប និងការពង្រឹងការអនុវត្តច្បាប់ម៉ឺងម៉ាត់ដើម្បីទប់ស្កាត់អំពើរំលោភសេពសន្ថវៈលើកុមារីមិនទាន់គ្រប់អាយុ។

ការកត់ត្រារបស់សមាគមសិទ្ធិមនុស្សអាដហុក(Adhoc) បានបង្ហាញថាករណីរំលោភចំនួន៥០១ករណីនៅទូទាំងប្រទេសក្នុងឆ្នាំ២០១០ដែលរួមមានចំនួន ៧៦ករណី ដែលជនរងគ្រោះមានអាយុតិចជាង១០ឆ្នាំ ចំនួន ៣៣ករណីដែលជនរងគ្រោះមានអាយុតិចជាង ៥ឆ្នាំនិងចំនួន ៧២ភាគរយ ដែលជនរងគ្រោះមានអាយុក្រោម ១៨ ឆ្នាំ នៅក្នុងឆ្នាំ ២០១០។ ចំនួនករណីរំលោភនេះបានកើនឡើងជិត៩ភាគរយពីចំនួន ៤៦០ករណី ក្នុងឆ្នាំ២០០៨ និងជិត២០ភាគរយខ្ពស់ជាងឆ្នាំ២០០៩ ដែលមានចំនួន៤១៩ករណី។

លោកឧត្តមសេនីយ៍ឯក **គៀត ច័ន្ទថារិទ្ធ** អ្នកនាំពាក្យប៉ូលិសជាតិបានថ្លែងប្រាប់វីអូអេ សំឡេងសហរដ្ឋអាមេរិកថានាយកដ្ឋានកណ្តាលប៉ូលីសយុត្តិធម៌កំពុងតែសិក្សាពីមូលហេតុនៃការកើនឡើងនូវបទល្មើសរំលោភសេពសន្ថវៈ និងរិះរកមធ្យោបាយបង្កើតផែនការយុទ្ធសាស្ត្រដើម្បីប្រយុទ្ធប្រឆាំងនឹងករណីរំលោភសេពសន្ថវៈនេះ។

"វិធានការសំខាន់ៗ ដើម្បីទប់ស្កាត់ការរំលោភសេពសន្ថវៈគឺ ទីមួយៈ ការអប់រំប្រជាពលរដ្ឋ និងការលើកកម្ពស់ការយល់ដឹងអំពីសីលធម៌សង្គមនិងតម្លៃនៃសង្គម ទីពីរៈ ការចាត់វិធានការបង្ការសកម្មភាពដែលកើតឡើង និងទីបី ៖ វិធានការច្បាប់ចុងក្រោយការអនុវត្តច្បាប់ត្រូវតែម៉ឺងម៉ាត់ និងដាច់ខាត"។

លោក **ធន សារ៉ាយ** ប្រធានសមាគមសិទ្ធិមនុស្សអាដហុក បានថ្លែងប្រាប់វីអូអេ សំឡេងសហរដ្ឋអាមេរិកថារដ្ឋាភិបាលមិនអាចទប់ស្កាត់អំពើរំលោភសេពសន្ថវៈតាមរយៈវិធានការច្បាប់តែមួយនេះ បានទេប៉ុន្តែរដ្ឋាភិបាលគួរតែចាត់វិធានការចម្រុះថ្មីៗបន្ថែមទៀត។

លោក **ធន សារ៉ាយ** បានបញ្ជាក់ថា រដ្ឋាភិបាលត្រូវតែយកចិត្តទុកដាក់លើការព្យាបាលជម្ងឺផ្លូវចិត្ត ពង្រឹងការអនុវត្តច្បាប់ផ្តន្ទាទោសជនល្មើស បង្កើនការបង្ក្រាបវីដេអូអាសអាភាស និងពង្រឹងការអប់រំសីលធម៌សង្គមឱ្យកាន់តែខ្លាំងក្លាឡើងថែមទៀត ព្រមទាំងលុបបំបាត់ការប្រើប្រាស់គ្រឿងញៀន។

លោក **ធន សារ៉ាយ** បានបន្ថែមថាបញ្ហាសង្គមពាក់ព័ន្ធនឹងបញ្ហាគ្មានការងារធ្វើ បញ្ហាភាពក្រីក្រ បញ្ហា អយុត្តិធម៌សង្គម បញ្ហានិទណ្ឌភាព និងបញ្ហាសេពគ្រឿងស្រវឹងដែលអាចធ្វើឱ្យមនុស្សមានវិបត្តិផ្លូវចិត្ត ទៅប្រព្រឹត្តអំពើចាប់រំលោភសេពសន្ថវៈ។

"ជារៀងរាល់ឆ្នាំ ចំនួនជនរងគ្រោះនៃការចាប់រំលោភសេពសន្ថវៈនេះចេះតែកើនឡើងដោយមិនឈប់សោះ ហើយក៏មិននៅទ្រឹងទៀត។ នេះជាការព្រួយបារម្ភ។ អញ្ចឹងហើយទាល់តែមានការសហការរួមគ្នាទាំងគ្រួសារ អង្គការសង្គមស៊ីវិល និងរដ្ឋាភិបាល។ ជាពិសេសរដ្ឋាភិបាលត្រូវតែមានវិធានការឱ្យបាន ម៉ឺងម៉ាត់ម៉ត់ចត់ ទើបយើងអាចទប់ស្កាត់បញ្ហារឿងចាប់រំលោភនេះបាន"។

លោកឧត្តមសេនីយ៍ឯក **គៀត ច័ន្ទថារិទ្ធ** បានថ្លែងថាក្នុងរយៈពេលពីរឆ្នាំចុងក្រោយនេះ បទល្មើសផ្សេងៗទាំងអស់បានថយចុះប៉ុន្តែបទល្មើសរំលោភសេពសន្ថវៈនេះបានកើនឡើង ទោះបីជាអាជ្ញាធរប៉ូលីសខំប្រឹងប្រែងយ៉ាងណាក៏ដោយ។

"ការប្លន់បានថយចុះដល់ទៅ ៣០ ភាគរយ។ ឃាតកម្មបានថយចុះ១៣ភាគរយ។ ការលួចបានថយចុះ១៧ភាគរយ។ ការប្រើប្រាស់ហិង្សាដោយចេតនាបានថយចុះ៨ភាគរយ។ ដោយឡែកការរំលោភសេពសន្ថវៈបានកើនឡើងជាង២០ភាគរយ។ អញ្ចឹងនេះជាប្រធានបទមួយដែលពួកយើងខ្ញុំកំពុងតែខ្វល់ខ្វាយខ្លាំងជាងគេ។ យើងកំពុងតែសិក្សាបង្កើតផែនការយុទ្ធសាស្ត្រ"។

លោកឧត្តមសេនីយឯក **គៀត ច័ន្ទថារិទ្ធ** បានបញ្ជាក់ថាអគ្គស្នងការប៉ូលីសជាតិនឹងលើកយកករណីរំលោភសេពសន្ថវៈមកធ្វើជាប្រធានបទដ៏ក្តៅបំផុតដើម្បីពិភាក្សារកដំណោះស្រាយនៅក្នុងកិច្ចប្រជុំប្រចាំ ឆ្នាំ២០១០នៅក្នុងចុងខែមករានេះ។

លោកឧត្តមសេនីយឯក **គៀត ច័ន្ទថារិទ្ធ** បានអំពាវនាវដល់ប្រជាពលរដ្ឋគ្រប់រូបឱ្យបោះបង់ចោលអំពើល្មើសនៃកាមតណ្ហាខុសច្បាប់នេះ ដើម្បីកុំឱ្យក្លាយជាអ្នកទោសនៃកាមតណ្ហាដែលសង្គមស្អប់ខ្ពើម។

***ដោយ ជន សក្កា, វីអូអេខ្មែរ***

# កុមារមួយចំនួននៅតែប្រឈមនឹង ការមិនបានចូលសាលារៀន

រាជធានីភ្នំពេញ : ទោះបីជាមានការប្រឆាំង និងទប់ស្កាត់ការប្រើប្រាស់ពលកម្មលើកុមារយ៉ាងណាក៏ដោយ តែភាពក្រីក្ររបស់ក្រុមគ្រួសារបានជំរុញឱ្យពួកគេចេញទៅរកប្រាក់ទៅតាមសុខភាពដែលអាចធ្វើទៅបាន ដោយការរើសអេតចាយ បេះបន្លែ ឬក៏សុំទានជាដើម។ នៅតំបន់ខ្លះ កុមារក៏ត្រូវធ្វើការធ្ងន់ហួសកំលាំងមិនបានចូលសាលារៀន គឺដើម្បីរកប្រាក់មកផ្គត់ផ្គង់ក្នុងសង្គមគ្រួសាររបស់ខ្លួន។



រូបថត រស្មី: កុមារលក់បន្លែជួយសំរួលជីវភាពគ្រួសារ

ជាការពិតណាស់ ទោះបីច្បាប់បំបាត់អំពើហិង្សាលើកុមារ និងពលកម្មលើកុមារត្រូវបានរដ្ឋសភា ចេញឱ្យប្រើប្រាស់ដើម្បីទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារយ៉ាងណាក៏ដោយ តែបច្ចុប្បន្ននៅតាមទីប្រជុំជន ទីក្រុង ឬជនបទ ដាច់ស្រយាលតាមបណ្ដាខេត្ត-ក្រុងនានា ជាពិសេសនៅក្នុងរាជធានីភ្នំពេញ និងនៅតាមតំបន់ទេសចរណ៍នានា គេតែងសង្កេតឃើញកុមារចាប់ពីអាយុ៣ទៅ៤ឆ្នាំ ពី៦ទៅ៩ឆ្នាំដើរសុំទាន ឬប្រកបរបរលក់ដូរ និងដើររើសអេតចាយជាដើម ។ ការប្រឈមនឹងការបោះបង់ពីសាលារៀននេះ ដោយសារភាពក្រីក្ររបស់គ្រួសារកុមារនីមួយៗ។

ពលកម្មកុមារ គឺជាឧបសគ្គដ៏សំខាន់មួយជាលក្ខណៈសាកលធ្វើឱ្យប៉ះពាល់ដល់សុខភាពរបស់កុមារម្នាក់ៗ និងធ្វើឱ្យយឺតយ៉ាវដល់ការកាត់បន្ថយភាពក្រីក្រ និងកិច្ចប្រឹងប្រែងអភិវឌ្ឍន៍របស់ប្រទេសជាតិផងដែរ។ ជាការពិតណាស់កុមារនៅរាជធានីភ្នំពេញមានមួយភាគបានដើររើសអេតចាយទាំងយប់ទាំងថ្ងៃ និងមួយភាគទៀតដើរសុំទាននៅតាមដងផ្លូវ និងនៅតាមភោជនីយដ្ឋាននានាពេលរាត្រី។ រីឯមួយចំនួនទៀតទូលបន្លែលក់នៅតាមផ្លូវសាធារណៈ និងនៅតាមទីផ្សារនានាក្នុងរាជធានីភ្នំពេញមិនបានចូលរៀននោះទេ បញ្ហានេះក៏ព្រោះតែជីវភាពជាចំបងដែរ ។



រូបថត រស្មី: កុមារលក់បន្លែជួយសំរួលជីវភាពគ្រួសារ

រីឯនៅតំបន់ទេសចរណ៍នានាដូចជាភ្នំតាម៉ៅ ទន្លេបាទី និងនៅរមណីយដ្ឋានគិរីរម្យជាដើម គេសង្កេតឃើញកុមារជាច្រើនឈរនៅតាម ស្ពានតាមដងផ្លូវសំពះសុំទាន និងលក់ផ្កាឱ្យភ្ញៀវដែលទៅកំសាន្តលេងដោយមិនបានគិតពីការចូលសាលារៀនឡើយ ។ ពីមួយថ្ងៃទៅមួយថ្ងៃគិតតែខិតខំប្រឹងប្រែងរកប្រាក់មកជួយផ្គត់ផ្គង់ក្នុងសង្គមគ្រួសារជាមួយឪពុកម្ដាយ ៕

*កោះសន្តិភាព, ថ្ងៃអង្គារ ទី២ ខែវិច្ឆិកា ឆ្នាំ ២០១០*



## "ការរៀនសូត្រប្រកបដោយ បរិយាកាសរីករាយ"

គូរដោយ: កុមារា វ៉ាន់ ចាន់រ៉ា
មកពី អង្គការ PLAN កំពង់ចាម
ជ័យលាភីប្រឡងគំនូរចំណាត់ថ្នាក់លេខ ១ ឆ្នាំ ២០១០